ក្រុមជំនុំទំនៀមទម្លាប់
COMMISSION DES MOEURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៦ ខែមករា លេខ ១

ព.ស. ២៤៩៦ – គ.ស. ១៩៥៤

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|


— បធានកថា .................. ព្រះទេពមុនី យូរ- ប៉ុណ្ណ ..... ៣

— មនុស្សយើងមិនផុតពីទុក្ខ .......... លោកប៉ូ - ប៉ូ ........... ១៤

### ផ្នែកអក្សរសាស្ត្រ

— ភាគរភាពខាងពុទ្ធសាសនា ........ លោក ប៉ូ - ប៉ូ ........... ១៩

— ព្រះភជោភិទ ................. អ្នកស្រី ឆាំ - ជុំ ........... ២៤

— ការបណ្ដុះនិស្ស័យ (តមក)........ ព្រះមហាឧត្ដមវិជ្ជា ប៊ុង - ប៉ម... ៣០

— រឿងសាមកុក (តមក).......... ឧកញ៉ា នូ - កន......... ៣៦

— នាលះនឹងទមយន្តី ............. អ្នក ស្រី ស្រ៊ិន សារីយ៉ាន់...... ៤៦

— រឿងចិញ្ចៀនទិព្យ (តចប់)......... អ្នកស្រី ស្រ៊ិន សារីយ៉ាន់..... ៥១

— រឿងប៉ូលនឹងវីរ៉ស៊ីនី (តចប់) ....... លោក ផេង - ជ្រីវ ........ ៦៦

### កំណត់ទីនព្រឹត្តិការណ៍

— បុណ្យឈាបនកិច្ចសពឧបាសិកា រ៉ុត ... ព្រះគ្រូសង្ឃសត្ថា ប៉ុណ្យ-សម្អាន ៧៨



មួយឆ្នាំមាន ១២ សៀវភៅ — ដំឡៃជាវ ២០០ រៀល

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

## TABLE DES MATIÈRES

### PARTIE RELIGIEUSE


— Padhanakatha . . . . . . . . *Vén.* YOU-PONN . . . . . . 3

— L'homme ne peut se libérer de la souffrance . . . . . . M. BOU-PO . . . . . . . . . 14


### PARTIE LITTERAIRE


— La Solidarité selon la religion bouddhique . . . . . . . . M. BOU-PO . . . . . . . . . 19

— Brah Rajovada . . . . . . Mme CHHAM-CHHOM . . . . 24

— Education morale (suite) . . Vén. PEUNG-PAM . . . . . . 30

— Histoire de SAMKOK (suite) . . Oknha NOU-KAN . . . . . . 36

— Nala et Damayanti . . . . . Mme SRIN-SARIS-YANN . . . 46

— La bague magique (suite et fin) Mme SRIN-SARIS-YANN . . . 51

Paul et virginie (suite et fin) . M. PHENG-CHRIEU . . . . . 66


### NOTES ET CHRONIQUES


— Incinération de Mme RITH . . . Vén PONN-SOMPHEACH . . . 78


Prix d'abonnement annuel (comprenant 12 numéros): 200$00

### បធានកថា

# ព្រះទេពមុនី យូរ-ប៉ុណ្ណ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

---

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

សូមនមស្ការចំពោះព្រះអរហំសម្មាសម្ពុទ្ធដ៏មានជោគព្រះអង្គនោះ (ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព) ។

វេលានេះ នឹងសំដែងអំពីបធានកថា តបស្នងឆន្ទសទ្ធានៃសាធុជន អ្នកជ្រះថ្លាក្នុងព្រះបវរពុទ្ធសាសនា ដូចតទៅនេះ ៖

បធាន: ប្រែថា "សេចក្ដីព្យាយាម" គឺព្យាយាមញុំាងសាធារណប្រយោជន៍ទាំងបច្ចុប្បន្នទាំងបរលោក ឬញុំាងប្រយោជន៍ផ្ទាល់ខ្លួនឲ្យកើតឲ្យមានឡើង ហៅថា បធាន: ។

បធាន: នោះមាន ៤ យ៉ាងគឺ

១— សំវរប្បធាន: ព្យាយាមប្រយ័ត្នមិនឲ្យបាបកើតឡើង

២— បហានប្បធាន: ព្យាយាមលះបាបដែលកើតឡើងហើយ

៣— ភាវនាបធាន: ព្យាយាមធ្វើកុសលឲ្យកើតមានឡើង

៤ — អនុរក្ខនាបធាន: ព្យាយាមរក្សាកុសលដែលកើតឡើងហើយ ។

បធាន: ទាំង ៤ យ៉ាងនេះ បើសំដែងរួបរួមដោយកិច្ចមាន ២ យ៉ាងគឺ:

១— បហានកិច្ច កិច្ចដែលត្រូវលះបង់

២— ភាវនាកិច្ច កិច្ចដែលត្រូវចំរើន ។

អធិប្បាយ: បហានកិច្ច "កិច្ចដែលត្រូវលះបង់" នោះ គឺលះបង់នូវអំពើបាប; ពាក្យថាបាប សំដៅយកអំពើអាក្រក់៣ យ៉ាងគឺ កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ មនោទុច្ចរិត ៣ ។ កម្មដ៏ណាមកទាំង ៣ នេះសុទ្ធតែជាបាបទាំងអស់ ។ ក្នុងបាលីមានសំដែងអំពីបាប ៣ ពួកនេះច្រើនជាងចំណែកដទៃៗ ព្រោះបាបអម្បាលនេះ ជាប្រធានរបស់បាបទាំងពួង; សូម្បីបាបដទៃៗ ក៏រួមចូលក្នុងបាប ៣ ពួកនេះដែរ ។

បណ្តាបាបទាំងប៉ុន្មានដែលបានពោលមកនេះ ឥតមានចំណែកណា មួយដែលជារបស់គួរធ្វើ គួរប្រព្រឹត្តសោះឡើយ ។ សមដូចព្រះពុទ្ធដីកានៃព្រះភគវន្តមុនីដែលត្រាស់នឹងព្រះអានន្ទថា "ម្នាលអានន្ទ! តថាគតហៅ កាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ថាជាកិច្ចដែលបុគ្គលមិនគួរធ្វើដោយដាច់ខាត" ។ កាលបើបុគ្គលណាមួយដែលធ្វើអករណីយកិច្ចនោះដោយ កាយ វាចា ចិត្ត ហើយ ត្រូវដឹងខ្លួនចុះថាមុខជានឹងមានទោសពុំខាន ។

ឯទោសប្រព្រឹត្តទុច្ចរិតនោះ មាន ៥ យ៉ាងគឺ

១ – សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯងដែរ

២ – លោកអ្នកចេះដឹងរិះគន់មើល រមែងតិះដៀលបាន

៣ – កេរ្តិ៍ឈ្មោះអាក្រក់ រមែងល្បីឮខ្ចរខ្ចាយទៅសព្វទិស

៤ – វង្វេងភ្លេចស្មារតីក្នុងពេលដែលទៀបស្លាប់

៥ – ខាងមុខអំពីទំលាយខន្ធទៅ រមែងទៅកើតក្នុងទុគ្គតិ ។

បុគ្គលណាធ្វើបាបដូចបានពោលមកនេះ រមែងក្តៅក្រហាយក្នុងលោកទាំងពីរ គឺក្នុងលោកនេះ កើតទុក្ខក្តៅក្រហាយដោយគិតថា អាត្មាអញបានធ្វើបាបដូច្នោះ ៗ លុះច្យុតចាកលោកនេះទៅហើយ រឹងរឹតតែក្តៅក្រហាយជាងនេះទៅទៀត ។

ព្រោះហេតុនោះ បានជាព្រះអរហំសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា បាបនេះជាអំពើមិនគួរធ្វើ មិនគួរប្រព្រឹត្តឡើយ ។

ការណីយកិច្ច "កិច្ចដែលគួរចំរើន" នោះ គឺកម្មដែលកំចាត់បង់នូវសេចក្តីអាក្រក់ ហៅថាកុសល, ការដែលព្យាយាមធ្វើកុសលឲ្យកើតឲ្យមានឡើងហៅថា បំពេញកុសលឲ្យបរិបូណ៌ ។ កុសលនោះ បើសំដែងដោយឫសគល់ បានដល់ អលោភោ ការមិនចំពាក់ចិត្តនឹងទ្រព្យសម្បត្តិ គឺមិនចង់បាននូវទ្រព្យសម្បត្តិរបស់អ្នកដទៃ មិនលួចលាក់ឆក់ដណ្តើមបំបាត់ប្រវ័ញ្ចន៍ សង្កត់សង្កិនរឹបជាន់យកទ្រព្យសម្បត្តិរបស់គេ

ដោយឥតមេត្តា, អទោសោ មិនប្រទុស្ត គឺមិនខឹងមិនគេរៀនរកហេតុអ្នកដទៃឲ្យគេដល់នូវសេចក្ដីវិនាស, អមោហោ មិនវង្វេងភ្លេចស្មារតី ដោយអ្នកដទៃគេគម្រាម កំហែង បំភាន់គំនិតជាដើមឡើយ ។

មួយទៀត កុសលនេះបើសំដែងដោយទីកើតមាន ១០ ប្រការ គឺ

១ - ការឲ្យនូវវត្ថុគួរដល់បុគ្គលដែលគួរឲ្យដោយសេចក្ដីសង្គ្រោះ ឬបូជាគុណមានឲ្យដល់មនុស្សកំសត់ទុគ៌ត ឬបូជាដល់អ្នកមានសីលធម៌ និងមាតាបិតាជាដើម ហៅថា ទានៈ ។

២ - ការវៀរចាកអំពើអាក្រក់ដែលកើតអំពី កាយ វាចា មាន វៀរបញ្ចវេរជាដើម ហៅថា សីលៈ ។

៣ - ការធ្វើចិត្តឲ្យស្ងប់រម្ងាប់ចាកអកុសលធម៌ មាននីវរណធម៌ជាដើម ដោយសមថវិធីនិងវិបស្សនាវិធី ហៅថា ភាវនា ។

៤ - ការទំរុឌទំពេមអស្មិមានៈដែលកើតមានក្នុងចិត្ត ដោយសេចក្ដីគោរពក្រែង ចំពោះបុគ្គលដែលគួរគោរពក្រែង គឺជនដែលចំរើនដោយជាតិ ដោយវ័យ ដោយគុណ ហៅថា អបចាយនៈ ។

៥ - ការជួយខ្វល់ខ្វាយក្នុងកិច្ចការកុសល ហៅថា វេយ្យាវច្ចៈ ។

៦ - ការឲ្យនូវចំណែកបុណ្យដែលខ្លួនបានធ្វើហើយ ដល់អ្នកដទៃ ដោយមេត្រីចិត្ត ដើម្បីឲ្យគេត្រេកអរតាម ហៅថា បត្តិទានៈ ។

៧ ការអនុមោទនាត្រេកអរតាមនូវសេចក្តីល្អរបស់អ្នកដទៃដែលគេបានធ្វើហើយ ដោយចិត្តដែលប្រាសចាកសេចក្តីប្រណែនឈ្នានីស ហៅថា បត្តានុមោទនា ។

៨ - ការណែនាំបង្ហាត់បង្រៀនប្រៀនប្រដៅអ្នកដទៃ ឲ្យចេះចំណេះវិជ្ជាដែលឥតទោស ឬពន្យល់ប្រាប់គន្លងផ្លូវលោកផ្លូវធម៌ ឲ្យស្គាល់កិច្ចគួរធ្វើ និងមិនគួរធ្វើ ដែលប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ចំរើនក្នុងបច្ចុប្បន្ននេះ រហូតដល់សម្បត្តិសួគ៌ សម្បត្តិព្រះនិព្វានជាទីបំផុត ហៅថា ធម្មទេសនា ។

៩ - ការតាំងចិត្តស្តាប់ធម៌ ស្តាប់ពាក្យឱវាទ ពាក្យប្រៀនប្រដៅដោយប្រឹងឲ្យចេះចាំស្ទាត់ធ្វើកើត និយាយបាន ហៅថា ធម្មស្សវនៈ ។

១០- ការធ្វើទិដ្ឋិ គឺសេចក្តីយល់ឃើញរបស់ខ្លួនឲ្យត្រូវតាមគន្លងធម៌ដែលពិតមែន ហៅថា ទិដ្ឋុជុកម្មៈ ។

អំពើទាំង ១០ ប្រការនេះ ហៅថាបុញ្ញកិរិយាវត្ថុ គឺជាទីកន្លែងសម្រាប់កើតបុណ្យ ។ បុគ្គលណាបានធ្វើកុសលដូចបានពោលមកនេះ, បុគ្គលនោះរមែងបាននូវអានិសង្ស ៥ យ៉ាង គឺ:

១ - សូម្បីខ្លួនឯងក៏សរសើរខ្លួនឯង

២- អ្នកប្រាជ្ញទាំងឡាយលោកពិចារណាឃើញតាមការពិតហើយលោករមែងសរសើរ

៣– មានកិត្តិស័ព្ទពីរោះល្បីខ្ចរខ្ចាយទៅសព្វទិស

៤ – មិនវង្វេងភ្លេចស្មារតីក្នុងពេលធ្វើមរណកាល

៥ – រមែងទៅកើតក្នុងសុគតិ ។

បហានកិច្ច នឹង ភាវនាកិច្ចដែលបានសំដែងមកនេះ ជាដំណើរខាងផ្លូវធម៌ បើជាខាងផ្លូវលោកវិញ សំដៅយកការលះបង់នូវបុកពា មារយាទអាក្រក់ ក្រអឺតក្រអោង គោងកាច ខ្ជិលច្រអូស ដើរលេងស៊ីផឹក ចាយវាយទ្រព្យសម្បត្តិឥតប្រយោជន៍ ឥតសណ្ដាប់ធ្នាប់ ធ្វើចោរកម្មលួចប្លន់ឆក់ដណ្ដើម រឹបជាន់សង្កត់សង្កិនយកធនធានអ្នកដទៃជាដើម ។ អំពើអស់នេះ សុទ្ធតែជាអំពើនាំឲ្យថោកទាបឲ្យទន់ខ្សោយឲ្យអាប់រស្មីដល់ខ្លួនឯង នឹងប្រទេសជាតិ មាតុភូមិ ជាអំពើនាំឲ្យលោកតិះដៀល; បុគ្គលអ្នកស្រឡាញ់សេចក្ដីល្អគួរលះបង់ចោល ។

ព្រោះហេតុនោះ យើងកើតមកជាមនុស្សម្នាក់ៗ ក្នុងលោកសន្និវាសនេះ មានអវយវៈគ្រប់គ្រាន់ មិនវិកលវិការៈ ដោយអាយតនៈណាមួយ គួរតែមានព្យាយាមបំពេញកិច្ចរបស់ខ្លួនឲ្យគ្រប់គ្រាន់ កុំពឹងផ្អែកទៅលើរូបបុគ្គលណាមួយឲ្យគេចិញ្ចឹមខ្លួននោះ មិនបានសម្រេចប្រយោជន៍ទេ, ព្រោះរូបនីមួយៗសុទ្ធតែមានសេចក្ដីសុខទុក្ខជាប់ទាក់ទងដោយកាយ, ឬក៏មានកាយជាទីអាស្រ័យនៃសេចក្ដីសុខទុក្ខ ដូចជាគេហដ្ឋានជាទីអាស្រ័យនៃមនុស្ស. ជីវិតសោតទៀតដែលនឹងតាំង

នៅបាន គឺព្រោះអាស្រ័យរាងកាយ ការគ្រប់គ្រងចិញ្ចឹមរាងកាយឲ្យបានធាត់ធំមាំមួនខ្លាំងពូកែទៅបាន ក៏ព្រោះអាស្រ័យសេចក្តីព្យាយាមស្វែងរកអាហារ, កាលបើប្រាសចាកអាហារហើយ សន្តតិរូបគឺរូបដែលចំរើនជាប់តទៅក៏ឈប់ចំរើន ទាំងជីវិតសោតទៀត ក៏តាំងនៅបានដោយក្រ ។ អាហារនេះជារបស់សំខាន់បំផុត សម្រាប់បម្រុងជីវិតឲ្យប្រព្រឹត្តទៅ, សមដូចបាលីថា សព្វេសត្តា អាហារដ្ឋិតិកា "ពួកសត្វកល់រូបដែលមានជីវិតរស់នៅបាន ក៏ព្រោះអាហារ" ។ វត្ថុឯទៀត ៗ ក្រៅពីអាហារនោះមានច្រើន ដូចយ៉ាងលំនៅជាទីជ្រកកោន សំពត់សម្រាប់ស្លៀកដណ្តប់ ថ្នាំសម្រាប់កែរោគក្នុងពេលដែលត្រូវការប៉ុណ្ណោះជាដើម, វត្ថុទាំងអម្បាលនេះ សុទ្ធតែជារបស់ជួយឧបត្ថម្ភទប់-ទល់ជីវិតទាំងអស់, បើប្រាសចាករបស់ណាមួយហើយ ជីវិតរមែងតាំងនៅបានដោយលំបាក ។

សូមទាញរឿងមហាជនកមកសំដែងក្នុងទីនេះ ដើម្បីឲ្យឃើញអានិសង្សនៃសេចក្តីព្យាយាម ។

ព្រះពោធិសត្វព្រះនាម មហាជនក កាលលាមាតាចុះសំពៅទៅជួញជាមួយនឹងពួកឈ្មួញ, លុះដល់កណ្តាលមហាសមុទ្រ សំពៅក៏ធ្លុះធ្លាយទៅដោយត្រូវខ្យល់ព្យុះខ្លាំង, ពួកឈ្មួញទាំងអស់ក៏ស្លាប់អស់ទៅ ។ ចំណែកខាងព្រះពោធិសត្វ មិនភ័យតក់ស្លុតនឹងសេចក្តីស្លាប់ឡើយ,

លោកនឹកដល់គុណមាតាបិតា នឹង គុណសីលដែលធ្លាប់បានប្រព្រឹត្តមក ហើយក៏លោតចេញអំពីសំពៅប្រឹងហែលសំដៅទៅរកត្រើយម្ខាង អស់ចំនួន ៧ ថ្ងៃ, លុះដល់ថ្ងៃឧបោសថ លោករក្សានូវឧបោសថសីលទាំងកំពុងព្យាយាមហែលក្នុងមហាសមុទ្រ ។

ពេលនោះ មានទេពធីតា ១ អង្គឈ្មោះ មណិមេខលា នៅរក្សាមហាសមុទ្រ បានឃើញព្រះពោធិសត្វប្រឹងព្យាយាមហែលមិនមានឈប់យ៉ាងនេះ ក៏ស្រែកសួរថា:

"អ្នកណានេះ កាលបើមិនឃើញនូវកោះត្រើយសោះ ម្តេចក៏ខំប្រឹងហែលក្នុងកណ្តាលមហាសមុទ្រ តើអ្នកដឹងនូវប្រយោជន៍ដូចម្តេច បានជាខំប្រឹងព្យាយាមហែលម៉្លេះ?" ។

ព្រះជនកពោធិសត្វតបថា:

"ម្នាលទេវតា! ខ្ញុំពិចារណានូវវត្តនៃសត្វលោក និងអានិសង្សនៃសេចក្តីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំបើទុកជាមិនឃើញនូវកោះត្រើយក៏ដោយចុះ ក៏នៅតែប្រឹងព្យាយាមហែលក្នុងកណ្តាលមហាសមុទ្រ (ទុកជាតម្រាប់ដល់លោក ស្លាប់ពេលណាឈប់ពេលនោះ មិនលះបង់នូវសេចក្តីព្យាយាមទេ)" ។

នាងទេពធិតាពោលថា:

"ត្រើយមហាសមុទ្រជ្រៅរកប្រមាណមិនបាន មិនប្រាកដដល់អ្នកណា ការព្យាយាមតាមកម្លាំងបុរស ក៏ជាការឥតអំពើដល់អ្នកនោះ អ្នកមិនដល់ត្រើយទេមុខជាទីងស្លាប់ ក្នុងកណ្ដាលមហាសមុទ្រនេះពុំខានឡើយ" ។

ព្រះជនកតបថា:

"បុគ្គល (កំពុងព្យាយាម សូម្បីទីងស្លាប់) ក៏បានឈ្មោះថាជាអ្នកមិនមានបំណុល គឺពួកញាតិពួកទេវតានឹងមាតាបិតាមិនបានតិះដៀលឡើយ បុគ្គលនោះ កាលបើបានធ្វើកិច្ចរបស់បុរសហើយ រមែងមិនក្ដៅក្រហាយក្នុងពេលខាងក្រោយឡើយ" ។

នាងទេពធីតាពោលទៀតថា:

"ការងារណាមិនសម្រេចដោយសេចក្ដីព្យាយាមទេ ការងារនោះទៅជារបស់ឥតផល មានតែសេចក្ដីលំបាកជាកម្រៃ សេចក្ដីស្លាប់រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះទីងមានប្រយោជន៍ដូចម្ដេច ដោយការព្យាយាមនោះ" ។

ព្រះជនកតបថា

ម្នាលទេវតា ! បុគ្គលណាដឹងច្បាស់ថា ការងារមានទីបំផុតត្រៃពេកមិនសម្រេចទេ ហើយលះបង់ចោលបែរជា

វគ្រាជីវិតរបស់ខ្លួនទៅវិញ ក៏បន្ថយនូវសេចក្ដីព្យាយាមពោល ពេញ, បុគ្គលនោះគង់នឹងដឹងនូវផលនៃសេចក្ដីខ្ជិលច្រអូស នោះពុំខានឡើយ ។ ម្នាលទេវតា ! បុគ្គលពួកខ្លះក្នុងលោកនេះ កាលបើឃើញនូវផលនៃសេចក្ដីប្រាថ្នាហើយ រមែងប្រកប នូវការងារទាំងឡាយ ការងារទាំងនោះ ទោះបីសម្រេចក្ដីមិន សម្រេចក្ដី គួរតែខំប្រឹងព្យាយាមកុំខាន ។ ម្នាលទេវតា ! ក្រែងអ្នកបានឃើញនូវផល នៃសេចក្ដីព្យាយាមជាក់ច្បាស់ ដោយខ្លួនឯងដែរឬ? ជនទាំងឡាយឯទៀត ៗ លិចចុះក្នុង មហាសមុទ្រអស់ហើយ មកពីមិនមានសេចក្ដីព្យាយាម, ឯខ្ញុំតែម្នាក់ឯងទេដែលកំពុងហែលឆ្លងក្នុងមហាសមុទ្រ ទាំង បានឃើញអ្នកដែលស្ថិតនៅក្នុងទីជិតខ្ញុំ, ខ្ញុំនេះនឹងព្យាយាម តាមសមគួរដល់សេចក្ដីអង់អាច នឹងសមគួរដល់កម្លាំង, កាលបើខ្ញុំបានដល់ត្រើយនៃមហាសមុទ្រហើយ ខ្ញុំនឹងធ្វើនូវ សេចក្ដីព្យាយាមដែលបុរសគប្បីធ្វើនោះ ឲ្យបានសម្រេចជា ភិយ្យោភាព ។

លុះព្រះជនកពោធិសត្វពោលតែប៉ុណ្ណេះហើយ, ទេពធីតាក៏ស្ទុះទៅ ចាប់ដៃព្រះពោធិសត្វ ហើបទាញនាំយកទៅដាក់ដល់មិថិលានគរ, មិន យូរប៉ុន្មាន ព្រះពោធិសត្វក៏បានសោយរាជ្យក្នុងនគរនោះឯង ។

នាំរឿងក៏រមែកប៉ុណ្ណោះដើម្បីឲ្យឃើញថា គុណសម្បត្តិនៃសេចក្ដីព្យាយាមនេះ អាចឲ្យសម្រេចផលដល់បុគ្គលអ្នកមានសមត្ថភាព ។ បុគ្គលណា កាលបើមានសេចក្ដីពេញចិត្តក្នុងការបំពេញកិច្ចរបស់ខ្លួន ហើយព្យាយាមបំពេញកិច្ចនោះ ក៏បានឈ្មោះថាប្រសើរជាទីបំផុត ។ ខ្លួនស្លាប់បាត់ទៅមែនតែកេរ្តិ៍ឈ្មោះនៅល្អ, ខ្លួនស្លាប់ទៅចុះ កុំឲ្យតែស្លាប់សេចក្ដីព្យាយាម ។ សមដូចពុទ្ធភាសិតថា រូបំ ជិយ្យតិ មច្ចានំ នាមគោត្តំ ន ជិយ្យតិ រូបនៃសត្វទាំងឡាយរមែងស្លាប់ទៅ តែនាមនិងគោត្រមិនស្លាប់ឡើយ ។ វីរិយេន ទុក្ខមច្ចេតិ គេឆ្លងនូវសេចក្ដីទុក្ខបានដោយសេចក្ដីព្យាយាម ។

សំដែងអំពីបធានកថាចប់តែប៉ុណ្ណោះ, ។

សូមថ្វាយព្រះរាជកុសលចំពោះព្រះករុណា ជាម្ចាស់ជីវិត សូមព្រះអង្គស្ថិតនៅក្នុងសិរីរាជសម្បត្តិអស់កាលដ៏យូរអង្វែងទៅ! និងសូមឲ្យអស់លោកជាពលរដ្ឋធំ-តូច ព្រមទាំងពុទ្ធបរិស័ទទាំងឡាយក្នុងកម្ពុជរដ្ឋទាំងមូល បានសេចក្ដីសុខចំរើនជាកិះយ្យាភាព! ។

---

# មនុស្សយើងមិនផុតពីទុក្ខ(១)

## ឃុនបណ្ឌិតរក្សប៊ូ-ប៊ូ ស៊ៀបសៀង

---

ជីវិតរបស់យើងទាំងឡាយដែលមិនសប្បាយរីករាយមិនស្រស់បស់នោះ ជាគ្រឿងចង្អុលបង្ហាញឲ្យដឹងថា "យើងពល់គ្នារងទុក្ខ" ។

ហេតុអ្វីបានជាយើងរងទុក្ខ?

ហេតុតែជីវិតរបស់យើងគ្មានឥស្សរភាព ។

ហេតុអ្វីបានជាជីវិតរបស់យើងគ្មានឥស្សរភាព?

ហេតុតែយើងជាប់ចំណង ១០ ប្រការ ។ ចំណងទាំង១០នោះចងគ្រៀកយើងជាប់ណាស់ ប៉ុន្តែវាបន្ធូរឲ្យវែងបណ្តោយឲ្យយើងដើរត្រាច់ទៅបានតាមទំនើងចិត្ត តែក្នុងកំរិតវង្វង់ខ្សែដែលអនុញ្ញាតឲ្យយើងដើរប៉ុណ្ណោះ យើងនឹងដើរឲ្យហួសចេញក្រៅកំរិតខ្សែនោះទៅទៀតមិនបានទេ ប្រៀបដូចគោដែលគេចងនឹងស្នឹងហើយចេះតែដើរក្រឡឹងជុំវិញស្នឹងដូច្នោះ ។

ចំណងទាំង ១០ នោះ គេវេញបញ្ចូលគ្នាជាខ្សែ ១ ធុង ចុងខ្សែម្ខាងចងគ្រៀកខ្លួនយើងជាប់ ចុងខ្សែម្ខាងទៀតចងភ្ជាប់នឹងបង្គោលគ្រាក់មួយដ៏រឹងមាំមួនក្រៃលែង បើខ្សែនោះមិនទាន់សឹកដាច់ដរាបណា ជីវិត

---

១ អធិប្បាយអំពីធម៌ ១០ ជាគ្រឿងចងគ្រៀកមនុស្ស ( សំយោជន៍ ១០ ) តាមច្បាប់ពុទ្ធសាសនា លេខ ម. ៤៣៨ ទំព័រ ៦០៦... ។

របស់យើងក៏គ្មានឥស្សរភាពដកបនោះជាដាច់ខាត ហេតុនេះហើយបានជាយើងមិនផុតពីទុក្ខ នេះជាពាក្យឆ្លើយតបទីងប្រស្នាខាងដើម ។

ឯចំណងទាំង ១០ ប្រការនោះ វាចេះធ្វើឧបាយកលច្រើនយ៉ាងណាស់ វាចងយើងមិនឲ្យដឹងខ្លួនសោះ វាចេះធ្វើមាយាប្រលោមលួងលោមយើងឲ្យស្ងប់ចិត្តទៅតាមវា វាចេះធ្វើនក្លែកៈយើងឲ្យមើលឃើញខ្លួនវាថាជាខ្សែមាសសង្វារកងកដាំសុទ្ធតែត្បូងពេជ្រ យើងកើតចិត្តប្រតិព័ទ្ធស្នេហាទីងវាក្រែបស្មារតីស្ទើបរជីវិត លុះវាដឹងថាយើងក្រែបខ្លួនហើយវាទាញយើងសន្សឹមៗ បន្តិចម្តងៗ ឲ្យយើងធ្លាក់ខ្លួនទៅជាអ្នកទោសរបស់វា ឲ្យយើងទៅជាទាសភាពរបស់វា ហេតុនេះហើយបានជាជីវិតយើងគ្មានឥស្សរភាព ។

ចំណងទាំង ១០ ប្រការនោះ លោកអ្នកប្រាជ្ញខាងព្រះពុទ្ធសាសនាឲ្យឈ្មោះតាមភាសាបាលីថា សំយោជនៈ ប្រែថា "គ្រឿងចងមនុស្សសត្វ", មាន ១០ ប្រការគឺ ៖

បំណងទី ១.— សេចក្តីសំគាល់ខុសក្នុងរាងកាយទាំងមូលថា រូបរាងកាយនេះមានខ្លឹមសារ ទីង សំគាល់ថាខ្លួនយើងមានអំណាចពេញលេញ អាចបង្គាប់បញ្ជារូបរាងកាយខ្លួនឯងឲ្យបានដូចចិត្តប្រាថ្នារបស់ខ្លួន ហើយប្រកាន់យករាងកាយទាំងមូលនោះថាជារបស់ខ្លួនជាដើម, តាមការពិត គំនិតដែលសំគាល់ដូច្នោះខុសស្រឡះទាំងអស់ ។

ខ្មែរនេះភាសាបាលីហៅថា សក្កាយទិដ្ឋិ "សេចក្ដីយល់ឃើញថារាងកាយជារបស់ខ្លួនយើង" ។

បំណងទី២.— សេចក្ដីសង្ស័យថា ការរំដោះខ្លួនឲ្យផុតពីការកេតលត់ គឺសេចក្ដីប្រមាទស្រវឹង, សេចក្ដីល្អប្រពៃដែលអាចជប់ជីវិតឲ្យស្រស់ថ្លាបាន, ការធ្វើដំណើរជីវិតត្រង់ទៅកាន់វិថីនៃសេចក្ដីបរិសុទ្ធមានពិតមែនឬ ឬក៏គ្មានទេ ។ ខ្មែរនេះភាសាបាលីហៅថា វិចិកិច្ឆា "សេចក្ដីសង្ស័យ" ។

បំណងទី ៣.— ការមិនយល់ច្បាស់លាស់ ចូលចិត្តមិនត្រង់មិនត្រូវគន្លងការទូន្មានហាត់ពត់កាយវាចាឲ្យល្អបរិសុទ្ធ នឹងមិនយល់ច្បាស់នូវសេចក្ដីរៀបរយដែលជាប់ទាក់ទងនឹងការហាត់ពត់កាយវាចា ត្រឡប់ជាវង្វេងយល់ខុសថា អំពើនោះៗជាអំពើឲ្យកើតបុណ្យខ្លាំងពូកែ ឲ្យមានសេចក្ដីសក្ដិសិទ្ធិ ឯខ្លួននឹងស្អាតបរិសុទ្ធបាន ក៏ព្រោះតែសេចក្ដីសក្ដិសិទ្ធិនោះឯងជាដើមចម ។ ខ្មែរនេះភាសាបាលីហៅថា សីលព្វតបរាមាសៈ "ការបបោសអង្អែលគន់សីលនឹងវត្ត" ។

បំណងទី ៤.— ដំរេកគន់អារម្មណ៍ជាទីស្រឡាញ់ ដែលមានកំដៅយ៉ាងខ្លាំងក្លា ព្រះពុទ្ធជាម្ចាស់ទ្រង់ហៅថា រាគគ្គិ "ភ្លើងគឺរាគ" ។ ខ្មែរនេះភាសាបាលីហៅថា កាមរាគៈ "សេចក្ដីដំរេកគន់កាម" ។

បំណងទី៥.— សេចក្តីថ្នាំងថ្នាក់នៃចិត្តក្នុងកាលមានសេចក្តីក្រោធចូលមកគ្របសង្កត់ ។ ខ្មែរនេះភាសាបាលីហៅថា បដិឃៈ "សេចក្តីទ្ទើមឬថ្នាំងថ្នាក់នៃចិត្ត" ។

បំណងទី៦.— ចិត្តដែលជាប់ជំពាក់ក្នុងរូបធម៌ឬរូបភពដែលហួសទៅ ទាល់តែឃើញថារូបនោះជារបស់គួរត្រេកអរហើយក៏មានចិត្តជាប់ស្អិត ។ ខ្មែរនេះភាសាបាលីហៅថា រូបរាគ "ដំរេកក្នុងរូប" ។

បំណងទី៧.— ចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ដែលមិនមានរូបប្រាកដ គ្រាន់តែមានឈ្មោះជាគ្រឿងដឹង ទាល់តែឃើញថាអារម្មណ៍ទាំងនោះគួរត្រេកអរហើយជាប់ចិត្តស្អិតទៅ ។ ខ្មែរនេះភាសាបាលីហៅថា អរូបរាគ "ដំរេកក្នុងអរូប" ។

បំណងទី៨.— សេចក្តីសំគាល់ខ្លួនឯងថា ខ្លួនយើងជាមនុស្សម្នាក់ដែរ ហើយយកខ្លួនទៅប្រៀបនឹងអ្នកដទៃ ជាហេតុឲ្យលើកកំពស់ខ្លួនថាខ្ពស់ជាងគេឬថាស្មើនឹងគេ ឬក៏ដាក់ខ្លួនថាថោកទាបជាងគេ ។ ខ្មែរនេះភាសាបាលីហៅថា មានៈ "សេចក្តីប្រកាន់ខ្លួន" ។

បំណងទី៩.— សេចក្តីអណ្តែតអណ្តូងនៃចិត្តទៅតាមអារម្មណ៍នោះៗ សេចក្តីរាយមាយក្នុងអារម្មណ៍ ។ ខ្មែរនេះភាសាបាលីហៅថា ឧទ្ធច្ចៈ "សេចក្តីអណ្តែតអណ្តូង" ។

បំណងទី ១០.— សេចក្តីមិនដឹងខ្លួន មិនដឹងប្រមាណ ការដឹងមិនទាន់ យល់មិនទាន់ ។ ខ្សែនេះតាមភាសាបាលីហៅថា អវិជ្ជា "សេចក្តីមិនដឹង" ។

មនុស្សយើងជាបុថុជ្ជនអ្នកក្រាស់ដោយកិលេស អាចនឹងកាត់ខ្សែបំណងទាំង ១០ ប្រការដាច់ដែរឬទេ ?

អាចនឹងកាត់ដាច់បាន ប៉ុន្តែមិនមែនកាត់តែម្តងដាច់អស់ទាំង១០ទេ ត្រូវតែមានព្យាយាមកាត់ ១ សរសៃម្តង ២ សរសៃម្តង ដរាបដល់ដាច់អស់ទាំង១០ទើបយើងផុតពីទុក្ខ បើយើងកាត់ដាច់អស់ ៩ សរសៃហើយ នៅសល់តែ ១ សរសៃប៉ុណ្ណោះ ក៏យើងមិនទាន់ផុតពីទុក្ខដែរ ហេតុនេះយើងត្រូវតែព្យាយាមកាត់ឲ្យដាច់អស់គ្រប់ទាំង ១០ សរសៃ កុំឲ្យនៅសល់ ១ សរសៃឡើយ ។

ព្រះបរមគ្រូនៃយើងទ្រង់ត្រាស់ប្រាប់ថា "មនុស្សនឹងផុតចាកទុក្ខបាន ព្រោះសេចក្តីព្យាយាម" គឺព្រះអង្គទ្រង់បង្គាប់ឲ្យយើងមានព្យាយាមខំកាត់កិលេសទាំងអស់ មានសំយោជន៍ ១០ ប្រការនេះជាដើម ទើបយើងនឹងផុតចាកទុក្ខ ក្លាយពីបុថុជ្ជនទៅជាព្រះអរិយៈបាន នេះជាពាក្យឆ្លើយតបនឹងប្រស្នាដែលតាំងទុកខាងដើម ។

ចប់

---

# ភាតរភាពខាងពុទ្ធសាសនា

## បរិយាយ ពីការរាប់អានគ្នាដូចបងប្អូនក្នុងផ្លូវពុទ្ធសាសនា

លោក ប៊ូ-ប៉ូ រៀបរៀង

---

ភាពនៃការរាប់អានគ្នាដូចបងប្អូនរបស់មនុស្សក្នុងលោក តាមភាសាបាលីហៅថា "ភាតរភាព" ។

ភាតរភាពមានច្រើន, តែរួមជា ២ ប្រភេទ គឺភាតរភាពក្នុងផ្លូវលោក ១ ភាតរភាពក្នុងផ្លូវសាសនា ១ ។

ការរាប់អានគ្នា តាមភាពជាជនជាតិជាមួយគ្នា ជាវង្សត្រកូលជាមួយគ្នា ជាមិត្តសំឡាញ់នឹងគ្នា ចាត់ជាភាតរភាពក្នុងផ្លូវលោក ។

ការរាប់អានគ្នា តាមភាពជាអ្នកកាន់សាសនាជាមួយគ្នា ចាត់ជាភាតរភាពក្នុងផ្លូវសាសនា ។

សូមបរិយាយចំពោះតែភាតរភាពក្នុងផ្លូវព្រះពុទ្ធសាសនាម្យ៉ាង ។

មនុស្សមានជាតិផ្សេងគ្នា ទាំងប្រទេសក៏ផ្សេងគ្នា ប៉ុន្តែកាន់សាសនាព្រះពុទ្ធជាមួយគ្នា ដូចជនជាតិឥណ្ឌា លង្កា ភូមា ថៃ លាវ ជប៉ុន ចិន យួន និងខ្មែរយើងជាដើម (ទោះបីផ្សេងនិកាយ) ក៏ហៅថា "មនុស្សពុទ្ធសាសនិក" ឬ "ពុទ្ធបរិស័ទ" ដូចគ្នា ។

ពុទ្ធបរិស័ទគ្រប់ប្រទេសកាន់ព្រះពុទ្ធសាសនា បានយល់ច្បាស់ថា ទាំងមនុស្សទាំងសត្វក្នុងសាកលលោកសុទ្ធតែខ្លាចទុក្ខចង់សុខ, ខ្លាចស្លាប់

ចង់សៅគ្រប់រូប ។ ដោយគេយល់ច្បាស់ដូច្នេះបានជាគេត្រូវផ្សាយមេត្តាចិត្តអាណិតមនុស្សសត្វទៅ និង ត្រូវធ្វើការកុសលនានា គឺកាន់សីលមានះវៀរចាកការបៀតបៀនការសម្លាប់ ការលួចជាដើម ព្រមទាំងបរិច្ចាគទានមានសាងវត្តអាពមវិហារ សាលារៀន មន្ទីរពេទ្យជាដើម ក្នុងប្រទេសរៀងខ្លួន ឧទ្ទិសចំពោះព្រះសង្ឃជាពុទ្ធជិនោរសទាំង ៤ ទិស គឺព្រះសង្ឃជាតិខ្មែរចូលទៅសំណាក់ក្នុងវត្តលោកសង្ឃជាតិឥណ្ឌៀ ថៃ ភូមា លង្កា លាវ ជប៉ុន ចិន យួនក៏បាន, លោកសង្ឃជាតិទាំងនោះចូលមកសំណាក់ក្នុងវត្តលោកសង្ឃជាតិខ្មែរក៏បាន ឥតប្រកាន់ឡើយ ។

នេះជាអំពើរិតចំណងការគោរពរាប់អានមនុស្សពុទ្ធសាសន៍ដូចគ្នា ឲ្យចាក់ស្រេះជាប់គ្នាជាដរាបទៅ ។

នៅបច្ចុប្បន្នកាលនេះ ពួកពុទ្ធបរិស័ទនៅទ្វីបអាស៊ីខ្លះ អឺរ៉ុបខ្លះ បានរួមគ្នាបង្កើតសមាគមពុទ្ធសាសនាឡើងហៅថា "ពុទ្ធិកសមាគមពិភពលោក" មានទីសំណាក់ការធំនៅលង្កាទ្វីប ។ ប្រទេសខ្មែរយើងក៏បានរួមជាមួយផង, ហើយរៀងរាល់ប្រទេសបានបង្កើតពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ ជាសាខានៃពុទ្ធិកសមាគមពិភពលោកទៀត ដើម្បីជួយឧបត្ថម្ភសមាគមនេះឲ្យរឹងប៉ឹងនិងឲ្យរីកសាយទូទៅ ។ ប្រទេសកម្ពុជាយើងក៏បានបង្កើតដូចគេ ហៅថា "ពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ" មានទីសំណាក់ការបណ្តោះអាសន្ននៅមហាកុដិវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

ពុទ្ធិកសមាគមទាំងនេះ ជាសមាគមពង្រីកភាតរភាពខាងព្រះពុទ្ធ-សាសនាឲ្យរីកធំទូលាយ ។ ការពង្រីករបស់សមាគមនេះមានន័យផ្សេង ៗ គឺសាងវិជ្ជាឋានសម្រាប់រៀនពុទ្ធវចនៈជាភាសាបាលីភាសាសំស្ក្រឹតនិងភាសាបរទេស, ប្រែពុទ្ធវចនៈអំពីភាសាបាលីភាសាសំស្ក្រឹតនិងភាសាបរទេស, រៀបរៀងពុទ្ធវចនៈទុកជាក្បួនច្បាប់សម្រាប់រៀនប្រជាជន, បញ្ជូនគណៈធម្មទូតទៅផ្សាយព្រះពុទ្ធសាសនាទៅនានាប្រទេសទូទៅទាំងពិភពលោក; បញ្ជូននិស្សិតទៅរៀនពុទ្ធវចនៈជាភាសាបរទេសនៅនានាប្រទេស ដើម្បីឲ្យចេះរបៀបផ្សាយនូវព្រះពុទ្ធសាសនាដោយភាសាផ្សេង ៗ ដូចប្រទេសខ្មែរយើងបានបញ្ជូនឲ្យទៅរៀននៅប្រទេសឥណ្ឌា លង្កា ភូមា ជប៉ុនជាដើម ។

អាស្រ័យដោយព្រះពុទ្ធសាសនា ជាសាសនាមានរសតែមួយ គឺវិមុត្តិរសដូចមហាសមុទ្ទដែលមានរសតែម្យ៉ាង គឺរសប្រៃ ហើយដោយពុទ្ធបរិស័ទព្រួតគ្នាពង្រីក និងរិតសម្ពន្ធភាតរភាពខាងព្រះពុទ្ធសាសនាដូចថ្ងៃមកនេះថែមទៀត ក៏មានប្រជាជននៅអាស៊ីនិងអឺរ៉ុបជ្រះថ្លាកាន់តាមកាន់តែច្រើនឡើងជាលំដាប់ ។ កាលបើដូច្នេះ ភាតរភាពខាងព្រះពុទ្ធសាសនាក៏មានច្រើនឡើងតាមគ្នា ។

ចំណែកប្រទេសកម្ពុជាយើង ជាប្រទេសមានជាតិ សាសនា មហា-ក្សត្រ តាំងពីសម័យគោកធ្លកព្រែងនាយមក មិនដែលអាក់ខានទេគ្រាន់

តែសម័យមុន គេកាន់ព្រហ្មញ្ញសាសនា, សម័យកណ្ដាលគេកាន់ពុទ្ធសាសនាបែបមហាយាន សម័យឥឡូវគេកាន់ពុទ្ធសាសនាបែបហីនយានប៉ុណ្ណោះ, ភាតរភាពរវាងជាតិ សាសនា មហាក្សត្រ របស់ខ្មែរក៏ចេះតែមានជាប់ជាដរាបមករហូតដល់សព្វថ្ងៃនេះ ។

ព្រោះហេតុនេះ បានជាព្រាហ្មណ៍បណ្ឌិតជាតិខ្មែរ បានតាំងត្រៃសរណដ្ឋាន ៣ ប្រការគឺ “ជាតិ សាសនា មហាក្សត្រ” ទុកជាបាវចនាសម្រាប់ទូន្មានបញ្ជនតាជនកូនកម្ពុជរដ្ឋ ឲ្យគោរពនូវប្រពៃណីរៀងខ្លួន ដើម្បីសេចក្ដីសុខ - ចម្រើនទីរុងរឿងដល់កម្ពុជប្រទេស ។ ប្រជាជនជាតិខ្មែរទាំងពួងក៏បានស្វាធ្យាយបាវចនានេះចេះចាំសឹងគ្រប់គ្នា ។

ព្រះករុណាព្រះបាទសម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅប្រទេសកម្ពុជាជាអម្ចាស់ជីវិតលើត្បូងរបស់យើងសព្វថ្ងៃនេះ ទ្រង់ប្រកបដោយត្រៃសរណដ្ឋានទាំង ៣ ប្រការនេះ គឺ

១) ទ្រង់មានព្រះជាតិជាខ្មែរ ជាព្រះមហាក្សត្រអគ្គប្រមុខជាតិខ្មែរ ទ្រង់ស្នេហានឹងគោរពជាតិខ្មែរ ;

២) ទ្រង់ស្នេហានឹងគោរពព្រះមហាក្សត្រ ជាបុព្វបុរសរបស់ខ្មែរ;

៣) ទ្រង់ស្នេហានឹងគោរពព្រះពុទ្ធសាសនា ជាសាសនាផ្លូវការរបស់ប្រទេសខ្មែរ ។

ព្រោះតែព្រះអង្គស្នេហានឹងគោរព ជាតិ សាសនា មហាក្សត្រនេះហើយ បានជាទ្រង់ស៊ូប្ដូរព្រះជន្មបំពេញព្រះរាជបេសកកម្ម តាមតាំងឯក

រាជ្យបរិបូណ៌ដោយក្លាហានទាំងដោយសន្តិវិធី ជូនប្រទេសជាតិមាតុភូមិ ដោយមិនទ្រង់ព្រះវិតក្កដល់ការនឿយហត់ ដូចយើងបានដឹងឮឃើញប្រាកដក្នុងគ្រានេះ ឲ្យប្រទេសជាតិបានឡើងឋានៈជាឯករាជ្យសម្បូណ៌ ដូចបុរាណសម័យ រហូតដល់គល្បាវសាន ។

ព្រះរាជករណីយកិច្ចទាំងនេះ ត្រូវបានទុកក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាថាជាកល្យាណកិច្ចប្រសើរក្រៃលែង បណ្ដាលឲ្យប្រជាជនរួមជាតិ សាសនា មហាក្សត្រជាមួយព្រះអង្គ ស្នេហាស្វាមីភក្ដិសក្ការៈគោរពព្រះអង្គជាទីបំផុត នាំគ្នាដើរតាមផែនការព្រះអង្គដែលសន្មតនាមថា “ផែនការព្រះសីហនុ” ដោយសាមគ្គីភាពដ៏ក្លាហាន ដូចខ្មែរបុរាណសម័យព្រេងនាយ ។

មួយទៀត ដែលព្រះប្រិយមហាក្សត្ររបស់យើង ព្រះអង្គបានទទួលការស្នេហា - សក្ការៈ - គោរព អំពីប្រជាជនរួមជាតិដូចថ្ងៃមកនេះ អាស្រ័យដោយភាតរភាពរវាងជាតិ - សាសនា - មហាក្សត្រ ដែលប្រទេសខ្មែរធ្លាប់មានជាបវេណីអំពីបុរាណរៀងមកផង, ដោយព្រះអង្គបានបំពេញនូវភាតរភាពនោះ ឲ្យរឹងរឹតតែខ្លាំងក្លាថែមឡើងផង ។

# អ្នកស្រី ឆាំ-ធុំ នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែពីទស្សនាវដ្ដី «ហ្វ្រាង់. អាស៊ី» ខែឧសភា ឆ្នាំ ១៩៥៣

---

ក្នុងអតីតកាលដ៏អន្លែងឆ្នាំទៅហើយ មានព្រះមហាក្សត្រ ១ ព្រះអង្គ ទ្រង់ព្រះនាម ព្រះបាទព្រហ្មទត្ត សោយរាជ្យនៅនគរពារាណសី ជាស្ដេចមហាអំណាចក្នុងលោក ។ ព្រះបរមពោធិសត្វទេវបុត្រយាងចាកតុសិតសួគ៌ចូលមកចាប់បដិសន្ធិ ក្នុងផ្ទៃនៃអគ្គជាយានៃព្រះបាទព្រហ្មទត្ត ។ លុះគ្រប់ទសមាស ព្រះពោធិសត្វប្រសូតចាកឧទរព្រះមាតាដោយសួស្ដី ។ ក្នុងថ្ងៃទី ៣ អំពីថ្ងៃប្រសូតនោះ ព្រះមាតាបិតានិងព្រះញាតិវង្សបានធ្វើនាមករណមង្គលថ្វាយព្រះនាមព្រះពោធិសត្វថា ព្រហ្មទត្តកុមារ ។ ព្រះពោធិសត្វលុះចំរើនវ័យវិញ្ញូនាការ បានព្រះជន្ម ១៦ វស្សា ទ្រង់យាងទៅរៀនសិល្បនិងវិទ្យាសាស្ត្រគ្រប់យ៉ាង ឯនគរតក្កសិលា ។

កាលព្រះពោធិសត្វរៀនចប់សព្វសិល្បសាស្ត្រហើយ ក៏ស្ដេចយាងត្រឡប់មកកាន់ប្រទេសជាមាតុភូមិវិញ ។ លុះព្រះរាជបិតាព្រះអង្គទ្រង់ទីវង្គតទៅ ព្រះពោធិសត្វទ្រង់គង់លើស្វេតច្ឆត្រ សោយរាជសម្បត្តិជាដំណអំពីព្រះរាជបិតា គេថ្វាយព្រះនាមថាព្រះបាទព្រហ្មទត្ត ។ ចាប់តាំងអំពីព្រះអង្គសោយរាជ្យមក ទ្រង់ប្រព្រឹត្តទសពិធរាជធម៌ ទ្រង់មានតេជានុភាពច្រើន ទ្រង់កាត់ថ្លែងតុលាការ ឆ្ងាយចាកអគតិទាំងពួង ។ ដោយសារ

តែព្រះបរមពោធិសត្វគ្រប់គ្រងផែនដីដោយសីលធម៌ នាម៉ឺនមុខមន្ត្រីទាំង-ឡាយក៏តាំងនៅក្នុងសុចរិតយុត្តិធម៌ ក្នុងការវិនិច្ឆ័យនៃកិច្ចការទាំងពួង ។

សេចក្តីវិវាទ រាជអាមាត្យទាំងឡាយវិនិច្ឆ័យតាមលំអាននៃសុចរិត, គូវិវាទដែលប្រព្រឹត្តអំពើល្មើស ក៏វិនាសសាបសូន្យ លែងមានក្នុងព្រះនគរ ។ ការច្រលច្របល់អំពីក្តីក្តាំក៏ស្ងាត់សូន្យឈឹង ។ រាល់ថ្ងៃនាម៉ឺនមុខមន្ត្រីទាំងអស់មកប្រជុំនៅក្រសួងតុលាការ តែឥស្សរជនទាំងនោះ ឥតបានឃើញគូក្តីដល់ម្នាក់មកប្តឹងផ្តល់ទៀតទេ ហេតុនេះ សាលាក្រសួងតុលាការក៏គេបិទទ្វារអស់ ។

ខណៈនោះ ព្រះបរមពោធិសត្វទ្រង់ព្រះតំរិះថា “អាត្មាអញសោយរាជ្យ ប្រកបដោយទសពិធរាជធម៌ហើយ បានជាគ្មាននរណាម្នាក់មកប្តឹងឲ្យជំនុំជំរះសោះ, ជំលោះផ្សេងៗក៏រលាយបាត់បង់អស់, ក្រសួងតុលាការក៏បិទទ្វារសាលា ដោយគ្មានការធ្វើ, សព្វថ្ងៃនេះ នៅសល់តែការវិនិច្ឆ័យខ្លួនអាត្មាអញប៉ុណ្ណោះទេ បើអាត្មាអញនៅប្រព្រឹត្តទាស់ខុសត្រង់បទណា នោះត្រូវតែអញវិនិច្ឆ័យត្រង់បទនោះឲ្យជ្រះស្រឡះចេញហើយប្រកបជីវភាពឲ្យសមទៅតាមគុណធម៌” ។

ព្រះបរមពោធិសត្វលុះទ្រង់ព្រះរាជតំរិះដូច្នោះហើយ ទើបទ្រង់ត្រាស់សួរទៅរដ្ឋមន្ត្រីទាំងអស់ថា “អស់លោកទាំងឡាយ លោកណាបានឃើញកំហុសខ្ញុំដែរ?” ។ រដ្ឋមន្ត្រីទាំងឡាយបានក្រាបទូលតាម

ការណ៍ពិតរៀងខ្លួន តែសេចក្តីក្រាបទូលទាំងនោះ សុទ្ធតែសេចក្តីសរសើរព្រះអង្គតែម្យ៉ាង ។ ព្រះមហាក្សត្រិយ៍ទ្រង់ព្រះតម្រិះទៀតថា "ភយាគតិធ្វើឲ្យឥស្សរជនទាំងនេះ មិនហ៊ានពោលពីកំហុសអញទេដឹង ទើបនាំគ្នាសរសើរអញទៅវិញ" ។ ព្រះរាជាទ្រង់សន្និដ្ឋានថា "ព្រះរាជបុច្ឆានេះ ទុកជាមិនបានលទ្ធផលឡើយ" ទើបទ្រង់សួរទៅបណ្ដារាស្ត្រទៀត ។ ចាប់តាំងពីជនានុជនដែលនៅក្នុងព្រះបរមរាជវាំង នៅទីក្រុង រហូតដល់និគមជនបទ ក៏ឆ្លើយតបព្រះរាជសំនួរតាមដោយន័យដដែល ៗ សូម្បីតែជនដែលនៅជិតទ្វារក្រុងទាំង ៤ ក៏គ្មាននរណាម្នាក់ពោលអំពីចរិយាមិនប្រពៃរបស់ព្រះអង្គដែរ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ឮច្បាស់តែអំនួតចំពោះព្រះរាជចរិយាដែលប្រាសចាកទូរជំនៀលផ្សេងៗ ទើបទ្រង់ព្រះតំរិះថា "បើដូច្នោះ គួរតែអញចេញទៅសួរបណ្ដាជនក្នុងស្រុកស្រែទៀត" ។

ព្រះបាទព្រហ្មទត្តទ្រង់ប្រគល់ការផែនដីទៅព្រះរាជវង្សាភិបាល រួចស្ដេចយាងគង់លើព្រះទីនាំងរាជរថ ជាមួយនឹងនាយសារថីម្នាក់ ។ ព្រះរាជាក្លែងភេទព្រះអង្គជាជនធម្មតា ទ្រង់យាងចេញពីទីក្រុងទៅសួរអ្នកនៅក្រៅទីក្រុង រហូតដល់ប្រទេសជិតខាង តែគ្មានឮពាក្យអ្នកណាថាព្រះអង្គមានកំហុសសោះ ។ ព្រះបាទព្រហ្មទត្ត លុះឮតែពាក្យសរសើរព្រះអង្គដូច្នោះ ក៏យាងត្រឡប់ចូលព្រះនគរវិញ ទ្រង់ស្ដេចមកតាមមាគ៌ាដ៏ធំមួយ ។

ក្នុងសម័យនោះ ព្រះមហាក្សត្រិយ៍ប្រទេសកោសល ព្រះនាមព្រះបាទមល្លិក: (Mallika) សោយរាជ្យដោយសុចរិតយុត្តិធម៌ ។ ព្រះរាជាអង្គនោះ ក៏ទ្រង់សព្វព្រះរាជហឫទ័យចង់ជ្រាបនូវកំហុសព្រះអង្គដែរ ។ ព្រះបាទមល្លិក: ទ្រង់ត្រាស់សួរបណ្ដាជននៅក្នុងព្រះបរមរាជវាំងរហូតដល់ស្រុកស្រែចំការ, តែពាក្យក្រាបទូលនៃជនទាំងនោះគ្មានសម្រេចតាមព្រះរាជបំណងឡើយ ទើបទ្រង់យាងដោយរាជរថមកដល់ផ្លូវដែលព្រះបាទ-ព្រហ្មទត្ត ទ្រង់ស្ដេចយាងត្រឡប់មកនោះ ។ ព្រះមហាក្សត្រទាំងពីរព្រះអង្គជួបគ្នាត្រង់ផ្លូវចង្អៀតមួយ នាំឲ្យរាជរថទាំងពីរបៀសគ្នាមិនរួច ។

ខណៈនោះ នាយសារថីខាងព្រះបាទមល្លិក: និយាយទៅរកនាយសារថីខាងព្រះពោធិសត្វថា “ អ្នកចូរបររទេះអ្នក ថយចេញពីផ្លូវនេះទៅ” ។ នាយសារថីនៃព្រះពោធិសត្វតបវិញថា “ ខ្ញុំមិនថយទេ ព្រោះព្រះចៅផែនដីក្រុងពារាណសីព្រះនាមព្រហ្មទត្ត ប្រថាប់ក្នុងរទេះនេះ, ត្រូវអ្នកឯងថយរទេះទៅវិញ” ។ សារថីព្រះបាទមល្លិក:ពោលតបវិញថា “ ខ្ញុំក៏មិនត្រូវថយរទេះខ្ញុំដែរ ព្រោះព្រះមហាក្សត្រសោយរាជ្យនៅនគរកោសល ព្រះនាមព្រះបាទមល្លិក: ទ្រង់គង់ក្នុងរថនេះ ដូច្នេះចូរអ្នកថយរទេះអ្នកចេញទៅ ទុកផ្លូវថ្វាយព្រះករុណាជាអម្ចាស់របស់ខ្ញុំវិញ” ។

នាយសារថីនៃព្រះបាទព្រហ្មទត្តគិតថា “ ក្នុងរទេះខាងណោះពិតជាមានព្រះមហាក្សត្រប្រថាប់មែន ចុះអញត្រូវគិតធ្វើដូចម្ដេច” ។ លំដាប់

តមក នាយសារថីនោះគិតឃើញថា "មានតែឧបាយមួយទេ គឺអញត្រូវសួរពីព្រះជន្មនៃស្តេចនោះ បើព្រះរាជាអង្គណាមានព្រះជន្មតិចជាងនោះត្រូវឲ្យព្រះរាជរថនៃព្រះរាជាអង្គនោះថយចេញ ទុកផ្លូវឲ្យព្រះរាជរថនៃព្រះរាជាដែលមានព្រះជន្មច្រើនបរទៅ" ។ នាយសារថីនៃព្រះពោធិសត្វ កាលប្តេជ្ញាដូច្នោះហើយ ក៏សួរពីព្រះជន្មាយុនៃព្រះបាទមល្លិកៈ ប៉ុន្តែព្រះរាជាទាំងពីរព្រះអង្គមានព្រះជន្មដំណាលគ្នា ។ នាយសារថីនៃព្រះពោធិសត្វ យកវិត្ថានុភាព ព្រះរាជសម្បត្តិព្រះកិត្តិនាម នឹងវង្សត្រកូលនៃព្រះរាជាទាំងពីរព្រះអង្គមកធៀបគ្នាទៀត ក៏ឃើញស្មើគ្នា យកទំហំផែនដីក្នុងព្រះរាជអាណាចក្រនៃស្តេចទាំងពីរព្រះអង្គ មកប្រមាណមើលទៀត ក៏ឃើញមានទំហំ ៣០០ យោជន៍ដូចគ្នា ។

នាយសារថីនៃព្រះបាទព្រហ្មទត្តប្តេជ្ញាទៀតថា "ចូរយើងទុកផ្លូវឲ្យព្រះរាជាអង្គណាដែលមានគុណធម៌ក្នុងព្រះអង្គ ហេតុនេះអ្នកចូរប្រាប់ខ្ញុំមក តើព្រះរាជារបស់អ្នកឯង មានគុណធម៌យ៉ាងណាខ្លះ"? ។

នាយសារថីព្រះបាទមល្លិកៈ ក៏សូត្រពាក្យកាព្យថ្លែងនូវកំហុសដែលស្មានថាជាគុណធម៌របស់ព្រះរាជានៃខ្លួន ដូច្នេះថា:

អ្នកក្រោធខ្លាំង ស្តេចតតាំង ដោយក្រោធត,
អ្នកឥតធម៌ ចិត្តមិនល្អ ទ្រង់មិនល្អតប,
អ្នកកំណាញ់ ស្តេចផ្ចាលផ្ចាញ់ ដោយកំណាញ់ស្រប,
ទ្រង់ប្រកប ពាក្យមិនពិត ផ្ចាញ់មុសា ។

ខណៈនោះ នាយសារថីព្រះពោធិសត្វក៏ស្រែកយ៉ាងខ្លាំងៗថា "នែអ្នក! អំបាញ់មិញនេះ អ្នកពោលអំពីគុណធម៌របស់ព្រះរាជានៃអ្នកឬ?" ។

- "បាទ" ។ - បើចរិយាបែបនេះ ហៅថា គុណធម៌ ចុះកំហុសស្តេចរបស់អ្នកឯងយ៉ាងណាទៅវិញ?" ។ សារថីព្រះបាទមល្លិកៈពោលតបថា "បើចរិយានេះ ទុកជាខុស, ចុះក្នុងរឿងនេះ តើព្រះរាជានៃអ្នកប្រព្រឹត្តចរិយាបែបណា ដែលចាត់ថាជាគុណធម៌?" ។

នាយសារថីនៃព្រះបាទព្រហ្មទត្តឆ្លើយតបថា "ចូរអ្នកចាំស្តាប់ចុះ ខ្ញុំនឹងថ្លែងអំពីគុណធម៌របស់ស្តេចខ្ញុំឥឡូវនេះ" រួចហើយក៏សូត្រនូវពាក្យកាព្យថា :

អ្នកក្រោធខ្លាំង ស្តេចតតាំង ដោយមិនក្រោធត,
អ្នកឥតធម៌ ចិត្តមិនល្អ ទ្រង់ល្អតប,
អ្នកកំណាញ់ ស្តេចផ្ចាលផ្ចាញ់ ដោយមិនកំណាញ់ស្រប,
ទ្រង់ប្រកប ពាក្យដ៏ពិត ផ្ចាញ់មុសា ។

ព្រះបាទមល្លិក និងនាយសារថីរបស់ព្រះអង្គ លុះបានស្តាប់នូវកាព្យជាសុភាសិតនេះហើយ ក៏ចុះពីរទេះ ដោះសេះចេញ ហើយអូសរទេះថយ ទុកផ្លូវថ្វាយព្រះបាទព្រហ្មទត្តឲ្យស្តេចយាងទៅ ។

ចប់

## ការបណ្ដុះនិស្ស័យ

### ព្រះមហាឧត្តមវិជ្ជា ធិលញ្ញាណោ ប៊ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណានុរក្ស ប៊ូ-ប៉ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យ

(តមក)

---

ការចេះធ្វើជានាយចៅហ្វាយលើខ្លួនឯងនេះ មានការចេះបង្គាប់បញ្ជាខ្លួនឯង, ការចេះទូន្មានខ្លួនឯង និងការចេះបង្ហាត់បង្ហឹកខ្លួនឯងជាលក្ខណៈ មានការស្គាល់ខុសត្រូវ ជាបេះដូង អង្វរករខ្លួនឲ្យចេះនឹករលឹកដល់សេចក្ដីខុស-ត្រូវ អាក្រក់-ល្អ វៀរចាកការដែលគួរវៀរ ប្រព្រឹត្តការដែលគួរប្រព្រឹត្ត និងវៀរចាកអាក្រក់ប្រព្រឹត្តល្អបានខ្លួនឯង នេះជាគោលនៃការចេះគ្រប់គ្រងខ្លួនឯង ។ អ្នកដែលស្គាល់ខុស ត្រូវ អាក្រក់ ល្អ ដោយវិធីបង្គាប់បញ្ជាខ្លួនឯង ទូន្មានខ្លួនឯង, និងហ្វឹកហ្វឺនខ្លួនឯង នេះហៅថាចេះគ្រប់គ្រងខ្លួនឯងបាន ។ អ្នកគ្រប់គ្រងខ្លួនឯងបាន មិនប្រព្រឹត្តអាក្រក់ ដោយភាពយ៉ាងនេះ រមែងប្រព្រឹត្តល្អគ្រប់ទ្វារ មិនប្រើរាងកាយដែលខ្លួនបានមកដោយកម្រ នោះឲ្យធ្វើការទុច្ចរិត ។ គឺធ្វើតែតាមផ្លូវដែលជាសុចរិត និយាយសំដីសុចរិត និងគិតរឿងដែលជាសុចរិត មិនគិតរៀបរប ប្លន់លួចបញ្ឆោតអ្នកណា សូម្បីសេពគប់មិត្តភក្តិក៏រក្សាសេចក្ដីយុត្តិធម៌ មិនយកប្រៀបមិត្តភក្តិ ប្រព្រឹត្តខ្លួនជាមនុស្សពិត មនុស្សត្រង់

មនុស្សយុត្តិធម៌ ឬទៀងត្រង់ជានិច្ច ។ អ្នកដែលចេះបង្ហាប់បញ្ញាខ្លួន ទូន្មានខ្លួន បង្ហាត់ខ្លួន ឲ្យជាអ្នកមានទឹកចិត្តល្អរៀបរយស្គាល់ខុស - ត្រូវ អាក្រក់ ល្អ - បាប ខុស ដូច្នេះ សូម្បីនៅក្នុងការគ្រប់គ្រងរបស់អ្នកដទៃ ក៏គង់ស្ងប់ស្ងៀមរៀបរយជារបៀបពបសា, មិនមានការចលាចលក្រវល់ក្រវាយ មិនមានការភ្ញាក់ផ្អើលស្លុតចិត្តរហូតដល់កើតហេតុ, មិនមានការញាប់ញ័រដោយអណ្ដាតរបស់មនុស្សព្រោះញោះញង់ចាក់រុកក្នុងផ្លូវខុស ទាំងមិនមានសេចក្ដីរំភើបចិត្តចំពោះហេតុការណ៍ក្រៅបន្តិចបន្តួចឡើយ ។

អ្នកមានការស្គាល់ខុស - ត្រូវនោះ សូម្បីទង្វើប្រព្រឹត្តល្មើសដោយកាយ វាចា - ចិត្ត. មើលងាយធេសប្រហែសចំពោះគំណាបទាំងបុគ្គលដោយមិនមានស្មារតីឃុំគ្រង ឬប្រព្រឹត្តខុសច្បាប់ទម្លាប់ដែលត្រឹមត្រូវដោយមានចេតនា ឬមិនមានចេតនា កាលបានដឹងថាខ្លួនខុសហើយក៏សម្ដែងសេចក្ដីក្ដៅក្រហាយ អង្វរករសូមលន់តួទទួលសារភាពទោសតែម្ដង មិនបាច់នរណាបង្ខំ ដែលចាត់ថាជាផ្លូវនាំឲ្យបានទទួលសេចក្ដីករុណាអត់ឱនចំពោះកំហុសតាមទោសានុទោស ឬកាលមានអ្នកដទៃធ្វើខុសចំពោះខ្លួន ក៏ឲ្យអភ័យ មិនប្រកាន់ទោស ដែលចាត់ថាជាការកំចាត់បង់សេចក្ដីខុសឲ្យសាបសូន្យមិនគិតយកឈ្នះ តែតាមអំពើចិត្តដែលចាត់ជាគ្រឿងបង្កទោសទាំងសេចក្ដីខុសឲ្យចំរើនក្រៃលែងឡើង ។

ពិតមែន ការព្រមទទួលលើកទោសឲ្យដល់អ្នកដែលមានកំហុសចំពោះខ្លួនយើង ឈ្មោះថាយើងធ្វើសេចក្ដីល្អយ៉ាងក្រៃលែងចំពោះគេ

ជាឧបាយឲ្យគេធ្វើសេចក្ដីល្អតបវិញ  នឹងជាឧបាយធ្វើឲ្យអ្នកដែលទាស់ចិត្តទៅជាមិត្តនឹងគ្នាបាន  ចាត់ថាជាសេចក្ដីល្អចំពោះខ្លួនយើងយ៉ាងទ្វេគុណ ។ បើយើងនាំគ្នាស្គាល់ខុស-ត្រូវ អាក្រក់-ល្អដូចគ្នាទាំងអស់ហើយ  មុខជាមិនមានការធ្វើទោសចំពោះគ្នានឹងគ្នាឡើយ  ព្រោះអ្នកទាំងសងខាង មានសេចក្ដីករុណានឹងលើកទោសឲ្យដល់គ្នានឹងគ្នាឯងៗ ។ ឯការព្រមទទួលសារភាពកំហុស នឹងការអត់ទោសចំពោះគ្នានោះ ចាត់ថាជាការធ្វើទោសនឹងការលើកលែងទោសចំពោះខ្លួនដោយខ្លួនឯង ។

អ្នកមិនស្គាល់ខុស-ត្រូវ មិនទាន់ឈ្មោះថា ជាមនុស្សចេះគ្រប់គ្រងខ្លួនឯងឡើយ  ព្រោះបណ្ដោយឲ្យនិស្ស័យអាក្រក់ចូលមកផ្ចាញ់ភាពជាធំក្នុងខ្លួនឯងបាន  ធ្វើខ្លួនឯងឲ្យធ្លាក់ទៅក្នុងអំណាចខាងបាប  គឺលោភ, ក្រោធ, វង្វេង, ឥច្ឆា, ឫស្យា, ព្យាបាទ, ខ្ចាប់ក្រែង  នឹងការញាប់ញ័រចិត្តចំពោះហេតុភេទផ្សេងៗ  មានអំណាចខាងការការពារខ្លួនតិចតួចតួចទាបណាស់ មិនល្មមនឹងគ្រប់គ្រងខ្លួនឯងដោយហេតុផលបានឡើយ រមែងបរាជ័យធ្លាក់ខ្លួនទៅជាឈ្លើយ  របស់សេចក្ដីអាក្រក់យ៉ាងងាយៗ ហើយនឹងត្រូវទំលាក់ខ្លួនចុះទៅកាន់សេចក្ដីវង្វេងវិលវល់ខ្សោយកម្លាំង  មានចិត្តវៀចទៅវៀចមកតាមអំណាចខាងបាប  ចាត់ថាជាមនុស្សបណ្ដោយខ្លួនឯងឲ្យល្ងង់ខ្លៅថោកទាប  ប្រកបការងារឡើងតាមបង្គាប់សេចក្ដីថោកទាបគ្រប់យ៉ាង  ចូលចិត្តតែក្នុងការទំលាក់បំផ្លាញមនុស្សដទៃ  ដើម្បីប្រយោជន៍សុខរបស់ខ្លួនឯង ។

ថ្ងៃនេះ បើប្រសិនណាជាលោក-អ្នកគ្រប់គ្រងខ្លួនឯងបាន លោក-អ្នកក៏អាចនឹងបានទទួលសុភមង្គល មានសុខ, មានពរ នឹងមានប្រាជា ឈ្លាសវាងវៃឡើងជាងកាល ៥ ឆ្នាំដែលកន្លងមកហើយ ។ ពិតមែនកាលបើយើងមិនអាចបង្គាប់បញ្ជាខ្លួនឯងបានហើយ សូម្បីមនុស្សដទៃក៏យើងមិនអាចនឹងបង្គាប់បញ្ជាឲ្យនៅក្នុងសំដីរបស់យើងបានដែរ សូម្បីនឹងបង្គាប់បញ្ជា ដោយឲ្យរបស់ជាទីគាប់ចិត្ត, ដោយសេចក្ដីករុណា, ដោយប្រតិបត្តិល្អគប់, ដោយទទួលធ្វើការឲ្យបានយ៉ាងល្អបំផុត, ដោយនីតិធម៌ ក៏បង្គាប់បញ្ជាមិនបានទាំងអស់ ។ ចំណែកខ្លឹមសារនៃការគ្រប់គ្រងខ្លួនឯងមានតែម្យ៉ាង គឺនឹងទូនក្នុងការដឹងខុស-ត្រូវ មិនធ្វើអ្វីតាមតែសេចក្ដីគាប់ចិត្ត មិនទទួលរបស់អ្វីអំពីនរណាមួយ បើមិនមានហេតុផលល្មមសមគួរ, មិនធ្វើ, មិននិយាយ, មិនគិតរឿងអ្វីៗ ដែលមិនសមហេតុ សមផល ។ ពិតមែនហើយ យើងនឹងធ្វើអ្វីក៏ធ្វើបានតាមចិត្ត តែត្រូវប្រយ័ត្នកុំធ្វើតែតាមគាប់ចិត្តក្នុងផ្លូវខុស ដែលជាហេតុជំរុញខ្លួនឯងឲ្យធ្លាក់ទៅក្នុងជ្រោះជ្រៅ គួរដំណើរខ្លួនតាមហេតុផលវៀរចាកការធ្វើតាមគាប់ចិត្ត ក្នុងរបស់ដែលគ្មានហេតុផល នឹងធ្វើតាមគាប់ចិត្តតែក្នុងវត្ថុដែលមានហេតុមានផល ដោយការដឹងខុស-ត្រូវរបស់ខ្លួនឯង ។

អ្នកដែលត្រូវគ្រប់គ្រងខ្លួនឯងនោះ មិនត្រូវទៅតៀមសុរាដើម្បីបរិភោគឲ្យស្រវឹងរហូតដល់ទប់ស្មារតីមិនជាប់ មិនត្រូវធ្វើអត្តវិនិបាតកម្ម

ដោយបាញ់ខ្លួនសម្លាប់ ឬចងកសម្លាប់ ឬក៏លេបថ្នាំសម្លាប់ឡើយ ត្រូវកែខៃដោយការបណ្តុះនិស្ស័យបង្ខាប់បញ្ជាខ្លួន, ខ្នះខ្នែងខ្លួនទីងបង្ខាប់ខ្លួនឯងឲ្យនៅក្នុងអំណាចនៃការដឹងខុសត្រូវរបស់ខ្លួនឯង, ព្យាយាមធ្វើចិត្តឲ្យរឹងប៉ឹង លើកខ្លួនឡើងធ្វើជានាយលើហ្វាយលើហេតុការណ៍ ដែលចូលមកឲ្យកឲ្យយ នាំឲ្យកើតសេចក្តីប្រែប្រួលកន្ទល់ សៅហ្មង ឬរញ្ជាក់ដុំទិសនោះឡើង គ្រប់គ្រងខ្លួនឲ្យចេះពិចារណាឃើញឧបាយដ៏ល្អក្នុងវត្តគ្រប់យ៉ាង ឲ្យស្អប់ខ្ពើមគំនិតក្នុងផ្លូវដែលមិនល្អ ឲ្យផ្លាស់ចិត្តមកគិតតែវត្តដែលចំរើនរ័យវឌ្ឍន៍ទីងរបស់ដែលល្អ ទីងឲ្យចេះស្គាល់លំដាប់ការងារ ត្រូវចូលទៅពិនិត្យមើលក្នុងកាលដែលធ្វើការងារណាមួយ មិននាំរឿងដទៃចូលមកប្រឡាក់ប្រឡូស ត្រូវព្យាយាមៈឈ្លាកធ្វើតែការងារដែលកំពុងធ្វើឲ្យសម្រេច ។

ការគ្រប់គ្រងខ្លួនឯង រមែងត្រូវការសេចក្តីផ្ចាប់ ដូច្នេះ ត្រូវទម្លាប់ខ្លួនឲ្យចេះរម្ងាប់សេចក្តីអាក្រក់ដែលមាននៅក្នុងខ្លួន ទីងហាមប្រាមការពារគ្រោះខ្លួនកុំឲ្យភ្ញាត់ទៅកាន់សេចក្តីអាក្រក់ ដែលសេចក្តីធ្វេសប្រហែស ឬសេចក្តីរង្វើងនាំក្បួលមក សូម្បីគ្រាដំបូងក្រែងទីងជីងខ្លួន ត្រូវទទួលសេចក្តីតឹងចិត្ត តឹងកាយ លំបាក ជូរក៏ដោយ កាលៈបើព្យាយាមជំនះធ្វើជាប់តគ្នាទៅរហូតដល់ចុងក្រោយ ហើយ ក៏គេចទីងងាយជ័ងច្បាស់លាស់បាន ។ ឯការគ្រប់គ្រងខ្លួនឯងដែលងាយស្រួលនោះ មិនត្រូវចំប្រឹងសង្គ្រោះតែខ្លួនឯងឲ្យច្រើនពេកទេ ។ ការផ្ចាប់នេះរាប់ថាជាឧបការៈ

ដ៏ធំ របស់សេចក្តីប្រព្រឹត្តខ្លួនទៅ តែត្រូវប្រព្រឹត្តខ្លួនឲ្យភ្ជាប់ក្នុងវត្តដែលល្អ កុំបណ្តោយឲ្យខ្លួនមានសេចក្តីភ្ជាប់ក្នុងវត្តដែលអាក្រក់ឡើយ ។ ព្រោះសេចក្តីភ្ជាប់នោះ បើជាឧបការៈក្នុងសេចក្តីល្អ ហាក់ដូចជាមានព្រះមកប្រោស, បើជាឧបការៈក្នុងផ្លូវអាក្រក់វិញ ក៏ដូចជាមានមារពិភពមកផ្ចាញ់ ។ លោកអ្នកចូលទំលាប់ខ្លួនតែក្នុងវត្តដែលល្អដែលទុកដូចជាព្រះមកប្រោស កុំទម្លាប់ខ្លួនក្នុងវត្តដ៏អាក្រក់ដែលទុកដូចជាមារពិភពមកផ្ចាញ់ឡើយ ។

តាមពិត អ្នកប្រាជ្ញាយកឈ្នះសេចក្តីអាក្រក់ បើគ្មានការគ្រប់គ្រងឬបង្ហាប់ខ្លួនឯងឲ្យបានបទជាដំបូងទេ ក៏មិនមានឱកាសនឹងយកឈ្នះសេចក្តីអាក្រក់បានដែរ, នេះមិនមែនជារឿងភ្ញាក់ចិត្តទេ គឺជារឿងប្រុងប្រៀបខ្លួន ។ មនុស្សណាដែលជម្រុញខ្លួនឡើងទៅនៅក្នុងឋានៈជាន់ខ្ពស់ មនុស្សនោះគឺជាអ្នកប្រុងខ្លួន ដើម្បីឋានៈនោះដោយការគ្រប់គ្រងខ្លួនឯង, ដោយការសិក្សា និងដោយការប្រតិបត្តិទំលាប់ខ្លួនមកជាយូរឆ្នាំហើយ ។ ដូច្នេះចូរប្រុងប្រៀបខ្លួនឲ្យស្រេច ដើម្បីធ្វើតាមច្បាប់នេះគឺចូរធ្វើ, និយាយ គិតតែក្នុងវត្តដែលមានហេតុផល ដែលចង្អុលបង្ហាញថាជាសេចក្តីល្អចំពោះខ្លួននិងមនុស្សដទៃ និងចូរចៀសឃ្លាតផ្លាស់វិធីនៃការធ្វើ, ការនិយាយ, ការគិត របស់លោកអ្នកទៅតាមដំណឹង (សេចក្តីដឹង) ក្នុងកាលដែលដឹងថាខុស ឬទៅតាមមតិមនុស្សដទៃ ដែលអាចចង្អុលកំហុសនៃវិធីការរបស់លោកអ្នកបាន ។ (មានត)

# រឿងសាមកុក

## ភាគទី ១៧

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

---

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នករាជការផ្លាស់បើបានអាន
> នឹងបេះឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

កាលចូជូបានស្រុកឈីជីវហើយ ក៏តាំងស្ដាប់ដំណឹងនឹងប្រៀបប្រុងសេនាទាហានឲ្យមានកម្លាំងព្រមព្រៀងគ្នា រួចបង្គាប់ទាហានថា យើងត្រូវលើកទ័ពទៅតាមចាប់លីប៉ោងឯស្រុកហៃហ៊ីទៀត ។ ជៀយ៉ុកក៏ប្រឹក្សាឆ្លើយថា ដែលមហាឧបរាជនឹងលើកទៅវាយស្រុកហៃហ៊ីគ្រានេះ ខ្ញុំយល់ថាលីប៉ោនោះប្រៀបដូចសុនខទាល់ច្រក ក៏នឹងស៊ូប្រាំងត្រាតែអស់ដរេះទឹងកម្លាំង ប្រសិនលីប៉ោរត់ចេញទៅបាន មុខជានឹងទៅរកអួនស៊ុត បើលីប៉ោនឹងអួនស៊ុតគប់គិតគ្នាជាពួកមួយហើយ ក៏នឹងបានជាកងទ័ពធំ បើដូច្នេះ សុំឲ្យមហាឧបរាជចាត់ទាហានដែលមានថ្វីដៃ លើកទ័ពមួយ

ប៉ែកទៅចាំស្កាត់ផ្លូវនៅទីមាត់កំពង់ស្រុកហួយណាំ បើល័ះបាននឹងរត់ទៅរកអួនសុតវេលាណា គង់តម្រង់ត្រង់ទៅលើទីនោះ យើងនឹងបានស្កាត់ទុកកុំឲ្យចេញទៅបាន ប្រសិនបើអួនសុតនឹងលើកទ័ពមកជួយលីប៉ោវិញក៏គង់នឹងមកមិនរួច មួយយ៉ាងទៀត ស៊ិនគួន, អ៊ុនឡេ, ង៉ុន, សៀងហ៊ូ ដែលជាមេចោរបែកទ័ពពីគាន់សៀវគួនទៅនោះ ក៏មិនបានដឹងប្រាកដជាទៅតាំងនៅតំបន់ណា ខ្លាចក្រែងវាលើកមកជួយលីប៉ោ ដូច្នេះសុំឲ្យមហាឧបរាជលើកទៅកំចាត់ពួកចោរចេញសិន ។

ចូច្ចូថា យើងនឹងឲ្យឡេវពីទៅចាំស្កាក់អួនសុតនៅកំពង់ហួយណាំ តាមផ្លូវដែលពួកចោរនឹងលើកគ្នាមកជួយលីប៉ោនោះ អ្នកកុំវិតក្កឡើយ យើងនឹងទទួលធានាគិតរឿងនេះឲ្យបានស្រួល ។

ឡេវពីបានឮចូច្ចូថាដូច្នោះក៏ទទួលថា ដែលនឹងទៅចាំស្កាក់លីប៉ោនឹងអួនសុត ខ្ញុំនឹងសុំទទួលយកអាសា ។ ចូច្ចូក៏ទទួលយល់ព្រម ។ លុះវេលាព្រឹកឡើង ឡេវពីក៏ចាត់ឲ្យបុត្រកនឹងកាន់យ៉ុងនៅរក្សាគ្រប់គ្រួ, ខ្លួនឡេវពី, កួនអ៊ូ, តៀវហ៊ុយ, ស៊ុនខៀន ក៏លើកទាហានទៅតាំងទ័ពនៅកំពង់ស្រុកហួយណាំ, ឯចូច្ចូក៏លើកទ័ពទៅវាយស្រុកហៃហ្វី ។

កាលលីប៉ោទៅតាំងទ័ពនៅក្នុងស្រុកហៃហ្វីនោះ ស្បៀងអាហារក៏បរិបូណ៌គ្រប់គ្រាន់ គូស្នាមភ្លោះជុំវិញស្រុកក៏ជ្រៅទឹកដក់ពេញ កាលដឹងថាចូច្ចូលើកទ័ពតាមមក លីប៉ោមិនបានគិតនឹងចេញតច្បាំងនឹងចូច្ចូគ្រាន់តែ

ប្រុងប្រៀបរៀបសេនាទាហាននឹងគ្រឿងសស្ត្រាវុធ ឡើងយាមលើសើន បន្ទាយជាមាំមួន ៗ គាន់កុងនិយាយនឹងលីហ៉ាថា ឥឡូវចូចូលើកទ័ពមក មិនទាន់បានទីស្នាក់ជាមាំមួនទេ ហេតុម្ដេចក៏លោកនៅស្ងៀមមិនចេញទៅច្បាំងនឹងចូចូ បើបង្អង់ឲ្យចូចូតាំងបន្ទាយជាមាំមួនហើយ យើងក៏ធ្វើការលំបាក ៗ លីហ៉ាថា ៖យើងធ្វើសង្គ្រាមចាញ់ប្រៀបចូចូច្រើនក្ដារហើយ គ្រានេះយើងត្រូវបង្អង់តាំងខ្លួនឲ្យខ្ជាប់ខ្ជួននៅក្នុងស្រុកស៊ិន ចាំកាលណាចូចូលើកទាហានជួនគូបួលមកដល់ជើងកំពែង សឹមយើងចេញតទល់ គង់តែចូចូនឹងចាញ់ប្រៀបយើងជាប្រាកដ ៗ

កាលចូចូលើកទ័ពមកដល់ស្រុកហៃហ្វី ក៏តាំងទ័ពនៅជិតកំពែងស្រុកប្រហែល ១០សិន (៤០០ម.) ចូចូក៏ឡើងជិះសេះជួនគួរបួលទៅដល់ជើងកំពែង ហើយស្រែកហៅលីហ៉ាថា កាលគ្រាតាំងតុប្រែចិត្តក្បត់ផែនដី អ្នកឯងរិះគិតនឹងសម្លាប់តាំងតុចេញ គ្រានោះ ឈ្មោះអ្នកឯងមានសេចក្ដីគាប់ប្រសើរល្អនឹងរាជការជាច្រើន ឥឡូវអ្នកឯងត្រឡប់មកចូលគំនិតនឹងអួនស៊ុត ដែលជាមនុស្សក្បត់ផែនដីវិញ កិត្តិស័ព្ទក៏ជ្រួតជ្រាបទៅដល់ព្រះសោតព្រះកាណ៌នៃព្រះចៅហៀនតេ បានជាទ្រង់ព្រះពិរោធត្រាស់ប្រើយើងឲ្យលើកទ័ពមក បើវេលានេះអ្នកឯងលះបង់មិនទៅចូលគំនិតនឹងអួនស៊ុតទេ គឺមានចិត្តសុចរិតត្រង់នឹងផែនដីវិញ ក៏ចូរប្រញាប់ចេញមករកយើងដោយស្រួល យើងនឹងបានជួយកែខៃក្រាបពិតទូលព្រះចៅហៀនតេ

ឲ្យទ្រង់អនុញ្ញាតទោស ហើយចិញ្ចឹមឲ្យធ្វើជានាហ្មឺនតទៅ បើអ្នកឯងមិនចេញមករកយើងដោយស្រួលទេ តែយើងវាយយកស្រុកនេះបានហើយ អ្នកឯងត្រូវជាប់ខ្លួនជាប្រាកដក្នុងទោសជាមហន្ត ដែលខ្លួនបានធ្វើទុកមកពីមុននោះ ។

លីប៉ោស្រែកតបថា បើប្រសិនមហាឧបរាជមាន សេចក្តីករុណាដល់ខ្លួនខ្ញុំមែន ឲ្យលើកទ័ពថយទៅវិញឲ្យអស់សិនចុះ ខ្ញុំនឹងបានជួបជុំពិគ្រោះនឹងទីប្រឹក្សាជាក្រោយ ។

កាលបួចួនឹងលីប៉ោនិយាយឆ្លងគ្នានោះ តាន់កុងឈរពីក្រោយខ្នងលីប៉ោ បានឮកំចិនប្រទេះឡាតលើកដបង្អួលមកបួចួហើយបាញ់តម្រង់ទៅ ព្រួញក៏ត្រូវបំមួកបួចួ ។ ត្រឡេកមើលឃើញតាន់កុងឈរពីក្រោយខ្នងលីប៉ោ ក៏ស្រែកថា "អញសម្លាប់អាឯងឲ្យបាន អាឯងមិនរួចពីដៃអញទេ" ហើយក៏បំផាយសេះវិលមកដេញទាហានឲ្យលើកសន្ធឹងចូលទៅព័ទ្ធស្រុកហៃហ៊ូជុំវិញ ។ តាន់កុងនិយាយនឹងលីប៉ោថា បួចួលើកកងទ័ពមកពីស្រុកហ៊ូគោយួរខេ ហើយ ទាហានវាក៏បានសេចក្តីហត់នឿយណាស់ សុំឲ្យលោកបែងចែកទាហានយើងចេញទៅក្រៅស្រុក ខ្លួនខ្ញុំបាទនឹងទទួលនៅរក្សាត្រួតត្រាខាងក្នុង បើបួចួលើកទ័ពមកវាយស្រុកវេលាណា ត្រូវលោកព្រួតវាយខ្នងពីខាងក្រោយទ័ពបួចួ ។ ខ្ញុំបាទនឹងតទល់ពីខាងមុខ បើបួចួបែរទៅតនឹងលោកវិញ ខ្ញុំបាទនឹងលើកទាហានវាយសន្ធឹងពីខាងក្រោយទៅ សេចក្តី

ដែលយើងធ្វើកលបញ្ឆោតយ៉ាងនេះ គង់តែចូចូនឹងពារែកបែកខ្ញែកគងទ័ព ត្រឡប់ជាដាច់ស្បៀងអាហារគង់នឹងបរាជ័យមិនខាន ។ លីប៉ោយល់ត្រូវផង ក៏ចាត់ចែងសេនាធាហានទុកព្រម ហើយចូលទៅនិយាយនឹងនាងងៀមស៊ីជាករិយា ពណ៌នារឿងរ៉ាវឲ្យស្ដាប់តាមគំនិតដែលតាន់កុងគិតនោះគ្រប់ប្រការ ។

នាងងៀមស៊ីឆ្លើយថា ដែលលោកនឹងលើកទ័ពចេញទៅក្រៅស្រុកនោះ ប្រសិនជាអន្ដរាយ ធ្វើម្ដេចខ្ញុំនឹងបានព្យាបាលរក្សាលោក ។ លីប៉ោបានស្ដាប់ករិយាថាដូច្នោះ ក៏ទន់ចិត្តអាណិតករិយាព្រមមិនដឹងជាគិតប្រ-ការម្ដេច ក៏មិនបានចេញនិយាយការរាជការដល់ ៣ ថ្ងៃ ។ តាន់កុងក៏ចូលទៅជួបនឹងលីប៉ោនិយាយថា ចូចូលើកទ័ពរុករានទន្ទ្រានចូលមកដល់ជើងកំពែងហើយ ម្ដេចឡើយក៏លោកមិនអើពើនៅស្ងៀមដូច្នេះ ស្រុកនេះមិនអន្ដរាយដោយចូចូទេឬ? ។ លីប៉ោថា ដែលយើងគិតការទុកនោះឃើញនាំឲ្យព្រួយទទេទៅ ត្រូវតែយើងរិះគិតរក្សាស្រុកទុកឲ្យមាំមួនទៅចុះឃើញស្រួលជាជាង ។ តាន់កុងថា ខ្ញុំបាទបានឮថាស្បៀងអាហារកងកងទ័ពចូចូនៅស្ទួចស្ដើងណាស់ទៅហើយ ឥឡូវចូចូប្រើបំរើទៅនាំស្បៀងពីក្រុងហ៊ូតោទៀត សុំឲ្យលោកលើកទៅចាំស្កាត់ដណ្ដើមស្បៀងចូចូ ឃើញនឹងខូចការដោយស្នាដៃរបស់យើង ។ លីប៉ោយល់ត្រូវក៏ចូលទៅប្រឹក្សានឹងនាងងៀមស៊ីទៀត ។ នាងងៀមស៊ីឆ្លើយថា "ដែលលោក

ទុកចិត្តតាន់កុងឲ្យនៅរក្សាស្រុកនោះ ខ្ញុំយល់ថាតាន់កុងតស៊ូនឹងចូចូមិន
បានទេ បើលោកទៅហើយ កិច្ចការដែលនឹងរក្សាស្រុកខាងក្រោយ គង់
នឹងអន្តរាយ ខ្ញុំនឹងបែរមុខទៅសង្ឃឹមអ្នកឯណា កាលគ្រាលោកបោលខ្ញុំទុក
ក្នុងស្រុកទៀងអាននោះ កុំតែបានប៉ាំងស៊ីជួយរិះគិតបញ្ជូនខ្លួនខ្ញុំឲ្យចេញ
មកដល់លោកក៏ខ្ញុំមិនរួចខ្លួន ឥឡូវខ្ញុំមិនបានឃើញអ្នកឯណាដែលនឹងទី-
ពឹងបាន បើលោកលើកទ័ពចេញទៅគ្រានេះ នោះនឹងបានលាភសក្ការៈ
ប៉ុន្មានក៏ត្រូវលោកគិតដល់ទ្រូងខ្ញុំ ដែលជាគូកំសត់ក្រមនឹងគ្នានោះសិន
ចុះ" និយាយហើយក៏សោកាកិលាបឱបបាទលីប៉ោ ៗ ក៏មានចិត្តអាណិត
អាណាថពន់ប្រមាណណាស់ មិនដឹងបើនឹងរិះគិតកែប្រែយ៉ាងណា ក៏
ចូលទៅរកនាងតៀវសៀនដែលជាភរិយាបន្ទាប់ ហើយអធិប្បាយរាយ
រៀងឲ្យនាងតៀវសៀនស្តាប់ ។ នាងតៀវសៀនក៏ហាមឃាត់អង្វរករ
លីប៉ោ ដូចនាងង៉ៀមស៊ីគ្រប់ប្រការ ។ នាងតៀវសៀនឱបបាទា
លីប៉ោសោកាទួញយំ ៗ លីប៉ោក៏បបោសអង្អែលថា "នាងកុំតក្កជាទុក្ខ
ព្រួយឡើយ ទោះបីយ៉ាងណាបងក៏មិនបោលប្អូនឲ្យមានសេចក្តីអន្តរាយ
ទេ នឹងខ្លាចប៉ីដំណូបប៉ុនចូចូនោះ ទួននឹងសេះបងក៏មានកំឡាំងច្រើន
បងនឹងតាំងត្រួតត្រារក្សាស្រុកនេះឲ្យមាំមួន មិនឲ្យចូចូចូលមកបាន"
ហើយលីប៉ោក៏ត្រឡប់ចេញមកនិយាយនឹងតាន់កុងថា ដែលចូចូប្រើ
ទាហានចូលទៅនាំយកស្បៀងអាហារពីក្រុងហ៊ូតោនោះ គឺធ្វើបញ្ឆោត

ហើយជាកលឧបាយឲ្យយើងលើកទ័ពទៅចាំដណ្ដើមស្បៀង បើកាលណាយើងទៅឯណោះ វាជ៊ីងនឹងលើកទ័ពមកវាយយកស្រុកឯណោះ នឹងបានដោយងាយ ហេតុនេះ ខ្ញុំយល់ថានឹងលើកទ័ពទៅតាមពាក្យអ្នកនោះ ក៏គង់នឹងខូចការជាប្រាកដ ។

តាន់កុងព្លលីប៉ោថាដូច្នោះ ក៏មិនបានតបឆ្លើយថាដូចម្ដេច ក្រោកចេញដើរទៅក្រៅ ហើយនិយាយប្រាប់សេនាទាហានទាំងពួងថា យើងទាំងឡាយពល់គ្នាគងវេលានេះ ឃើញនឹងដល់នូវសេចក្ដីវិនាសអន្តរាយក្ស័យអាយុជីវិតប្រាកដហើយ ព្រោះលីប៉ោគិតការខុស ពុំបានយកតាមគំនិតប្រាជ្ញាអ្នកឯណាសោះ លីប៉ោមិនបានគិតនឹងចេញតតាំងច្បាំងនឹងប៉ូធូទេ បេះតែនាំនាងង៉ៀមស៊ី, នាងតៀវសៀន ផឹកស្រាជាអាចិន្ត្រៃ ត្រេកល្ហបប្រាថ្នានឹងឲ្យសោយសេចក្ដីទុក្ខលំបាក ។

ឯហៅគី, អង់កាយ ជាទីប្រឹក្សាឃើញលីប៉ោមិនបានគិតការសង្គ្រាមដូច្នោះ ក៏នាំគ្នាចូលទៅរំឭកថា ដែលលោកនៅស្ងៀមព្រងើយកន្តើយដូច្នេះ ស្រុកហៃហ្វីនឹងអន្តរាយអសារឥតការៈដោយប៉ូដៃចូធូជាប្រាកដហើយ សព្វថ្ងៃនេះអ៊ួនស៊ុតនៅស្រុកហ្វួយណាំ ក៏មានសេនាទាហានជាច្រើន សូមឲ្យលោកចាត់បម្រើទៅនិយាយនឹងអ៊ួនស៊ុតថា លោកនឹងលើកកូនក្រមុំឲ្យជាភរិយាកូនអ៊ួនស៊ុត ឲ្យអ៊ួនស៊ុតលើកកងទ័ពមកជួយវាយខ្លួប៉កងទ័ពចូធូ ។ ក៏គង់នឹងបែកខ្ញែកចេញមិនខាន ។ លីប៉ោយល់

ឃើញត្រូវតែធ្វើសំបុត្រឲ្យទៅតី, អង្គកាយ កាន់ចេញទៅឲ្យអ៊ិនស៊ុត ។ ទៅតីដកបថា ខ្ញុំបាទទីងស៊ុទា បានចេញជូនដំណើរទៅឲ្យផុតកងទ័ពចូឆូសិន ។ លីប៉ោក៏បាត់ប្រើគៀវលៀវជានាយទ័ពមុខ ប្រើឡាន់បេងជានាយទ័ពក្រោយលើកទាហាន ១.០០០ ចេញទៅ លុះពេលយាម ៣ យប់ ទៅតី, អង្គកាយ ក៏លាលីប៉ោចេញពីស្រុកហៃហ្វី ។ គៀវលៀវនឹងឡាន់បេង ទៅតី លើកទៅដល់ដែនហួយណាំ ។ ឡាន់បេងបែងទាហាន ៥០០ ទៅជាមួយទៅតី អង្គកាយ, ឲ្យគៀវលៀវនាំទាហាន ៥០០ ត្រឡប់មកស្រុកហៃហ្វីវិញ ហើយទៅតី, អង្គកាយ, ឡាន់បេង ក៏លើកចូលទៅក្នុងស្រុកហួយណាំ ចូលទៅជួបនឹងអ៊ិនស៊ុតយកសំបុត្រលីប៉ោជូនទៅឲ្យអ៊ិនស៊ុត។ លាមើលឃើញសេចក្ដីថា "ខ្ញុំលីប៉ោសូមគំនាប់មកអ៊ិនស៊ុត ដ្បិតអ្នកឲ្យបម្រើមកសុំកូនក្រមុំខ្ញុំ នឹងនាំទៅឲ្យកូនអ្នកនោះ ខ្ញុំនៅមិនទាន់រៀបមង្គលការ ព្រោះចូឆូលើកទ័ពមកជាច្រើនណាស់ លើសកំឡាំងខ្ញុំដែលនឹងបេញតទល់ ហេតុនេះ ខ្ញុំសុំឲ្យអ្នកលើកកងទ័ពមកជួយវាយខ្នងពីក្រោយ ដោយផ្លូវមេត្រីពប់តានគ្នាតទៅ" ។

អ៊ិនស៊ុតមើលសំបុត្រហើយក៏ថា លីប៉ោនេះជាមនុស្សនិយាយមិនមានពាក្យសត្យពិតត្រង់ៗ ណាសោះ កាលគ្រាមុននោះយើងឲ្យសំបុត្រទៅសុំកូនក្រមុំ លីប៉ោទទួលពាក្យថាព្រមឲ្យដល់យើង ឲ្យយើងរៀបទៅទទួលនាំយកតាមវិធីទៀម លីប៉ោក៏ត្រឡប់កែប្រែចាប់ខ្លួនហាន់អ៊ិនបញ្ជូ

ទៅឲ្យចួច  ហើយសម្រាប់តាហានបំរើផលយើងប្រើទៅទៀននោះទៀត ឥឡូវចួចលើកទ័ពមកពន្ធស្រុក ហេតុម្ដេចមិនពឹងប្រស័យចួច កំត្រឡប់បែរមុខមកពឹងយើងជាគួសត្រូវវិញ? ។

ខៅគីបានឮដូច្នោះ ក៏ឆ្លើយតបថា លីប៉ៅហៅហ្វាយខ្ញុំបាទទឹងបានគិតប្រទូសរ៉ាយទឹងលោកដូច្នោះកំទេ កាលលោកប្រើហានអ៊ុនទៅសុំកូនក្រមុំនោះ លីប៉ៅមានសេចក្ដីត្រេកអរណាស់ ព្រមលើកកូនក្រមុំឲ្យបំរើលោកនាំមកជូនលោកជាពិត តែថាវេលានោះចួចប្រែកលក្បាយផ្សេងៗ ទើបការនោះបែរត្រឡប់ខុសទៅ ឥឡូវលីប៉ៅធ្លាំមកដំរាបលោកថា ម្ដងនេះព្រមជូនកូនក្រមុំមកលោកជាប្រាកដហើយ ។

អ៊ួនសុតតបថា ឥឡូវលីប៉ៅប្រែហលគស៊ូទឹងចួចមិនបានហើយឬ? បានជាលើកកូនក្រមុំឲ្យយើង បើប្រសិនម្ដងណេះជាការពិតមែន កំត្រូវតែលីប៉ៅបញ្ជូនកូនក្រមុំមកឲ្យយើងសិន ទើបយើងទឹងលើកកងទ័ពទៅជួយ ដែលទឹងឲ្យយើងលើកទៅជួយជាមុននោះ យើងមិនទុកចិត្តជាប្រាកដទេ ព្រោះលីប៉ៅធ្វើឲ្យយើងរង្កៀសចិត្តម្ដងទៅហើយ ។ ខៅគីបានស្ដាប់កំមិនបានឆ្លើយតបថាម្ដេច ទើបលាអ៊ួនសុតនាំគ្នាចេញពីស្រុកហ្វួយណាំមកវិញ លុះមកដល់ប្រទល់ដែនឃើញបន្ទាយឡៅពីតាំងស្កាត់ទទឹងផ្លូវ ខៅគីទឹងអងកាយក៏និយាយទឹងឡាន់បេងថា យើងជាអ្នកកាន់សំបុត្រខ្ញុំនអ្នកជាសេនាលីប៉ៅៗ ប្រើឲ្យមកជួយការពារយើងមិនឲ្យមានសេចក្ដី

អន្តរាយ វេលាយប់នេះ យើងនឹងលបចេញទៅឲ្យផុតបន្ទាយទៀតពីចុះ អ្នកចូរនាំពលទាហានជួយការពារពីក្រោយឲ្យមាំមួន ៗ ឡាន់បេងទទួលពាក្យពេចន៍ស្រេចហើយ លុះដល់ពេលយប់ ចៅគី, ទឹងអងកាយ ក៏លបចេញទៅផុតបន្ទាយទៀត ឡាន់បេងក៏នាំទាហានការពារពីក្រោយ ៗ

គៀវហ៊ុយនៅក្នុងបន្ទាយបានឮសូរជើងមនុស្សដើរសន្ធឹកណាស់ក៏ទឹកសង្ស័យនាំទាហានចេញទៅមើល ឃើញឡាន់បេងលើកទាហានពារបន្ទាយឆ្លងទៅ គៀវហ៊ុយក៏បំផាយសេះដេញឡាន់បេងពីក្រោយ ឡាន់-បេងក៏ទាញសេះបែរមកតទីងគៀវហ៊ុយបាន ១ ភ្លែង គៀវហ៊ុយចាប់ខ្លួនឡាន់បេងបាន ឯទាហាន ៥០០ ក៏រត់បែកព្រាត់ព្រាយអស់ទៅ គៀវហ៊ុយក៏នាំខ្លួនឡាន់បេង ទៅជូនឡៀវពី ៗ សួរសាកដឹងសេចក្តីសព្វគ្រប់ហើយ ក៏ឲ្យបំរើឃុំនាំខ្លួនឡាន់បេងទៅឲ្យប៊ូឆ្វ ៗ សួរឡាន់បេងថា ខ្លួនឯងទៅណាមកណា? ៗ ឡាន់បេងក៏ឆ្លើយជំរាបតាមដំណើរពិតត្រង់ឲ្យប៊ូឆ្វស្តាប់ ៗ

(មានត)

# ណាលៈ និង ទមយន្តី

## រឿងព្រេងប្រទេសឥណ្ឌា

## អ្នកស្រីត្រាំង-សារិយ៉ាន់ ក្រុមពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ប្រែពីភាសាបារាំងមកជាខ្មែរ

---

### វគ្គទី ១

ព្រះបាទ វីរសេន (Viraséna) គ្រងរាជសម្បត្តិនៅប្រទេស និសធៈ (Nishadhas) ទ្រង់ព្រះសុវណ្ណគតទៅ មានព្រះរាជបុត្រាពីរព្រះអង្គ ព្រះរាជវង្ស ៗ ព្រះរាជបុត្រច្បងព្រះនាម ណាលៈ (Nala) មានរូបឆោមលោមពណ៌ល្អក្រៃលែង ស្មើឲ្យព្រះឥន្ទ្រាធិរាជ (Indra) ដែលជាម្ចាស់ស្ថានសួគ៌ កើតសេចក្តីប្រណែន, បើកាលណាទ្រង់យាងតាមផ្លូវក្នុងទីក្រុងនៅក្បាលក្បួនទ័ព គេឃើញទ្រង់ហាក់ដូចជាព្រះសុរិយាបញ្ចេញរស្មីគ្រប់ពណ៌ដែលគួរឲ្យចេតនា ។ ព្រះអង្គប្រកបដោយព្រះហឫទ័យក្លាហាន ទ្រង់បំពេញកិច្ចជាវីរបុរស ទ្រង់ជាក្សត្រគោរពសាសនា ទ្រង់ចេះចាំក្បួនខ្នាតនឹងវេទៈ (Véda) ហើយទ្រង់ទំនុកបំរុងពួកព្រាហ្មណ៍ណាស់ ៗ ជនណាដែលមានរាសនាបានឃើញទ្រង់ហើយ មិនអាចនឹងភ្លេចទ្រង់បានឡើយ តែងតែដើរផ្សាយនូវកិត្តិស័ព្ទពេញលោកទាំងមូល ។

ព្រះអនុជនៃព្រះបាទណាលៈ ព្រះនាម បុស្ការៈ (Pushkara) មានព្រះរូបកាយតូចហើយខ្សោយផង ទ្រង់សព្វព្រះហឫទ័យនៅតែក្នុងទីស្ងាត់

ហើយពួកប្រជានុរាស្ត្រ ក៏ពុំសូវបានឃើញទ្រង់ផង ។ នៅវេលាដែលព្រះបាទនាលៈ ធ្វើព្រះរាជពិធី, ព្រះអគ្គម្ចាស់បុស្ការៈ ច្រើននៅតែមួយព្រះអង្គឯង មិនចូលមកបង្ហាញព្រះអង្គក្នុងទីប្រជុំជនផងទេ ម្ល៉ោះហើយបានជាគេមិនអាចដឹងបានថាទ្រង់ជាក្សត្រអង់អាច ឬជាក្សត្រដែលមានព្រះបរិយាអន់ខ្សោយឡើយ ។ ជនទាំងឡាយតែងតែគិតថាទ្រង់សព្វព្រះរាជហឫទ័យគង់នៅក្នុងទីស្ងាត់តែម្នាក់ឯង មិនឲ្យអ្នកណាស្គាល់តែប៉ុណ្ណោះ ។

ចំណែកព្រះបាទនាលៈវិញ តែងទ្រង់សព្វព្រះរាជហឫទ័យខ្លាំងណាស់នឹងការបង្ហាត់សេះ ទោះសេះនោះសាហាវយ៉ាងណាក៏ដោយ ក៏ទ្រង់ពុំខ្លាចបន្តិចសោះឡើយ ទ្រង់ឡើងគង់លើក បញ្ចូលកទៅក្នុងនឹម ហើយបង្ហឹកឲ្យទាល់តែទៅជាស្លូតបូតបាន ។ នៅពេលដែលទ្រង់ចង់ក្រសាលម្តងៗ ទ្រង់បង្គាប់ឲ្យពួកសារថីដែលមានថ្វីដៃ មកប្រណាំងប្រជែង ប៉ុន្តែអ្នកទាំងនោះចាញ់ទ្រង់ទាំងអស់ ។

ជួនកាល ក្រោយពីការពិភាក្សាអំពីកិច្ចការក្នុងព្រះរាជអាណាចក្ររួចហើយ ទ្រង់ក្រសាលឡ្បុក-ឡ្បាក់ (៩៥) ដើម្បីនឹងលំហែព្រះហឫទ័យ ។ កាលណាទ្រង់មានជោគជ័យ ព្រះអង្គមិនទុកប្រាក់នោះទេ ទ្រង់ប្រទានទៅពួកតាបសនិងពួកអ្នកក្រីក្រ ។ ឯព្រះអគ្គម្ចាស់បុស្ការៈ ដោយឮសូរគេលេងទ្រហឹង ក៏ទ្រង់យាងចេញមកទតគេលេងដែរ ហើយចេះតែ

សំឡឹងប្រាក់ដែលព្រះបាទនាលៈលេងឈ្នះ ៗ លុះឃើញព្រះបាទនាលៈទ្រង់យកប្រាក់នោះបែកជាទានអស់ទៅ ទ្រង់ក៏លួចញាក់ព្រះអង្គរិះគន់ៗ

## វគ្គទី ២

នៅឯប្រទេស វិទភៈ (Vidarbhas) មានមហាក្សត្រមួយព្រះអង្គព្រះនាម ភិមៈ (Bhimas) គង់រាជសម្បត្តិ ទ្រង់ប្រកបដោយតេជានុភាពជាយ៉ាងក្រៃលែង ទ្រង់មានព្រះរាជបុត្រីមួយព្រះអង្គព្រះនាមទមយន្តី (Damayanti) ដែលប្រកបដោយរូបឆោមលោមពណ៌ល្អលើសលប់ស្រីទាំងឡាយ ៗ ព្រះភក្ត្រព្រះនាងល្អលើសវង់ព្រះចន្ទ្រ លំអនៃព្រះនេត្រព្រះនាងរកអ្វីផ្ទឹមគ្មាន ហាក់ដូចជាធ្វើឲ្យកើតសេចក្ដីរិះគន់ដល់ពួកកវីដែលសរសើរអំពីវិចិត្រនៃផ្កាឈូក មានសម្បុរបរិសុទ្ធដូចជាមាសទឹកដប់ មានព្រះកេសាវែងសំយុងប្រាសដី មានព្រះសុដន់ដូចជើងពានមានជីវិត មានបបូរព្រះឧស្ឋញញឹមស្រស់ប៉ប្រិម ដែលបង្ហើរព្រះសូរសៀងយ៉ាងស្រទន់ពីរោះ ហាក់ដូចជាគេច្រៀង ៗ

ព្រះបាទភិមៈ ទ្រង់សព្វព្រះរាជហឫទ័យ នឹងព្រះរាជបុត្រីណាស់ ហើយរើសយកស្រីក្រមុំយ៉ាងល្អ ៗ នៅក្នុងភូមិភាគនោះមកធ្វើជាស្នំព្រះនាង ប៉ុន្តែព្រះនាងនៅតែមានលំអលេចធ្លោជាងស្ត្រីទាំងឡាយទៅទៀត បីដូចជាផ្លេកបន្ទោរលេចឡើងកណ្ដាលពពកសម្បុរស្រអាប់ ៗ គេគ្រាន់តែក្រឡេកឃើញនាង ក៏មានចិត្តរីករាយទៅហើយ ពួកអ្នកដំណើរដែល

ដើរកាត់តាមប្រទេសទៃតៈ ក៏នាំសេចក្ដីសរសើរអំពីរូបល្អនៃព្រះនាង ទមយន្តី ទៅផ្សាយពេញពិភពលោក ។

ពេលវេលាដែលព្រះនាងទមយន្តី នឹងត្រូវរើសព្រះភស្ដាក៏កាន់តែជិតមកដល់ ។ ព្រះនាងបេះតែគង់ទ្រមឹង ព្រះទ័យអណ្ដែតអណ្ដូងជាខ្លាំង ។ កាលណាពួកស្រីស្នំមកស្លៀកពាក់តែងព្រះអង្គឲ្យព្រះនាងៗ ក៏នៅតែព្រងើយ មិនរវល់នឹងការសន្ទនានៃស្នំឡើយ ។ គេមកក្រាបទូលព្រះនាងជារឿយៗ ថា «ព្រះបាទនាលៈជាស្ដេចមួយព្រះអង្គ ដែលមានព្រះរូបល្អលើសលប់ក្សត្រទាំងអស់» ។

### វគ្គទី ៣

គេបានមកក្រាបទូលព្រះបាទនាលៈជាញឹកញយថា: «ព្រះនាងទមយន្តី ជាក្សត្រីល្អឆើតឆាយគេ» ។ ព្រះបាទនាលៈក៏បេះតែទ្រង់ព្រះតម្រិះគិតមមៃទៅរកព្រះនាងទមយន្តី ។ ទ្រង់គង់នៅក្នុងព្រះរាជដំណាក់មិនសុខសោះ ហើយទ្រង់បេះតែធុញទ្រាន់នឹងការពិភាក្សានៃពួកនាហ្មឺនសព្វមុខមន្ត្រី ។ ទ្រង់មានព្រះបន្ទូលយ៉ាងខ្លីៗ ជាមួយនឹងរាជទូតស្ដេចជិតខាង ហើយទ្រង់បេះតែរកទីស្ងាត់ ។

ព្រះបាទនាលៈទ្រង់ស្ដេចទៅសម្រាំក្នុងឧទ្យានតែមួយព្រះអង្គឯង នៅក្រោមម្លប់នៃដើមឈើដែលមានផ្កាក្រអូបឈ្ងុយ ហើយទ្រង់ផ្ទុំទ្រាលនៅលើស្មៅដែលមានផ្កាព្រោងព្រាត ។

ទ្រង់ធ្មេចព្រះនេត្រពព្រិមៗ ។ នៅក្នុងពន្លឺព្រិលៗ ព្រះអង្គស្រមៃ ទតទៅឃើញដូចជាខ្មោចស្ងួនៗ ហើយទ្រង់ខំស្រែកថាៈ " ហ្នឹងហើយឬ នាងទមយន្តី? ស្រីសំឡាញ់បងមកនេះ ប្អូន!" បន្តិចមកស្រមោលនោះ វិនាសបាត់ទៅ ព្រះអង្គទ្រង់គង់នៅទាំងមានព្រះទ័យវិតក្ក ។

ថ្ងៃមួយ ព្រះអង្គទតយល់ក្ងានព្រៃជាច្រើន ដែលមានសម្បុរស្លាប ដូចមាស ហើរចុះពីលើមេឃសំដៅមកក្នុងគុម្ពោតដែលទ្រង់គង់ ។ បក្សី នោះចុះមកទំក្បែរព្រះអង្គៗ ក៏ឈោងព្រះហស្តទៅក្របួចក្ងានមួយ ស្រាប់ តែក្ងាននោះពោលថាៈ "ឱព្រះមហាក្សត្រ! សូមទ្រង់កុំសម្លាប់ទូលបង្គំ មិនសមនឹងស្លាប់ដោយជោគវាសនាអាក្រក់យ៉ាងនេះទេ ។ បើទ្រង់ ប្រោសប្រណីទុកជីវិតឲ្យទូលព្រះបង្គំ ទូលព្រះបង្គំនឹងថ្វាយរង្វាន់ ដល់ព្រះអង្គវិញ មិនខាន ។ ទូលព្រះបង្គំនឹងហើរទៅឯប្រទេសវិទភៈ ហើយទូល ព្រះបង្គំនឹងទូលព្រះនាងទមយន្តីថា ព្រះបាទនលៈ ដែលជាចមកពមាន ព្រះហឫទ័យប្រតិព័ទ្ធចំពោះព្រះនាង នោះព្រះនាងមុខជានឹងលែងរវល់ នឹងស្តេចឯណាក្រៅពីទ្រង់ទៀតហើយ" ។

ព្រះបាទនលៈ ទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ញញឹម, គេឃើញ ព្រះនេត្រព្រះអង្គមានទឹកដមយ៉ាងថ្លា ដែលបណ្តាលមកអំពីសេចក្តី សប្បាយ ។ ក្ងានព្រៃក៏ហើរសំដៅទៅឯប្រទេសវិទភៈ ។

(មានត)

# រឿងចិញ្ចៀនទិព្វ

## អ្នកស្រីសារិយ៉ាន់ ប្រែរៀបរៀង

(ត-ចប់)

---

ស្រីបំរើងាកទៅសួរគ្នាវិញ ហើយក៏បើកឲ្យទ្រង់ចូល ។ លុះទ្រង់យាងចូលទៅទ្រង់ទតឃើញយាយចាស់អង្គុយ មានស្រីបំរើនៅអង្គុយអមត្រៀបត្រា ។ យាយចាស់លុះឃើញស្តេចយាងចូលទៅស្ទុះមកទទួល "អ្នកស្រីអញ្ជើញ!" ។ ព្រះអង្គម្ចាស់អាលីទ្រង់សួរថា: 'យាយមិនស្គាល់ខ្ញុំទេឬ?" ។ រួចទ្រង់បើកសំពត់គ្របមុខទ្រង់ចេញហើយចាប់ដៃយាយមកថើប ។ យាយចាស់ស្រែកថា "ឱ កូនមាសម្តាយ! ទ្រង់អាលីតើ" ហើយក៏ឱបរិតព្រះអង្គម្ចាស់អាលីទាល់តែសន្ទប់បាត់មាត់ ។ លុះភ្ញាក់ខ្លួនឡើងកាលណា គាត់សួរស្តេចថា 'កូនកែវម្តាយ!, ចូរកូននិយាយរឿងកូនប្រាប់ម្តាយផង តើមានរឿងរ៉ាវអ្វី?" ។ ទ្រង់អាលីក៏និយាយរៀបរាប់រឿងរ៉ាវរបស់ខ្លួនតាំងតែពីដើមដល់ចប់ ។ យាយចាស់ស្តាប់ហើយ បែបជឿងទើបថា "កូនអើយ! ហ្នឹងហើយជាការណ៍ដែលម្តាយខ្លាចជួសកូន ល្មើយលែងរលាស់ទៅកូន! តើឯងមានបំណងយ៉ាងណា?" ។ ទ្រង់ឆ្លើយតបថា: "ខ្ញុំនឹងយកចិញ្ចៀននោះឲ្យបានហើយនឹងបំផ្លាញមេចង្រៃឲ្យបានដូចបំណង" ។

— មិនអីទេ ចាំម្តាយជួយឲ្យសំរេចសេចក្តីដែលឯងប្រាថ្នា ។

ពួកស្រីបំរើនាំគ្នាលេងសប្បាយទទួលម្ចាស់ដែលទើបនឹងហោងមកដល់ថ្មី ៗ យាយតាស់ចូលទៅក្នុងបន្ទប់ទឹក យកខ្លួននឹងខ្លាញ់ ប៊ឺរ (Beurre jondu) កិនលាយគ្នាហើយលាបខ្លួនគាត់ត្រង់កន្លែងដែលត្រូវលុតជន្លង់ គាត់ថ្វាយបង្គំហើយកន្លែងនោះទៅជាខៅ បើនរណាឃើញគាត់នៅពេលនោះ ទីងស្មានថាគាត់ជាអ្នកសមាទានសីល គាត់ស្លៀកសំពត់អាវអំបោះ ហើយទទូរក្រមាពេមបៀមកាន់ក្អមមួយមានទឹកពេញ ហើយមានប្រាក់១ពាន់ឌីណានៅក្នុងបាតក្អមនោះ ដែលគាត់គ្របដោយសំពត់មួយ ហើយក៏ចេញដើរទៅដល់ដំណាក់ព្រះនាងវរពជិនី ៗ លុះគាត់ចូលទៅដល់មាត់ទ្វារ គាត់ឃើញមានពាងទឹកមួយនៅក្នុងល្វែងប្រចាំការ ឃើញមនុស្សបំរើទីងពួកខ្លួយកាន់ក្អមទៅដងទឹកពីក្នុងពាងនោះ ៗ ពួកបំរើសួរគាត់ថា: "យាយមានការអ្វី? ត្រូវការទឹកឬ?" ៗ ដូនជីលុះឮគេសួរដូច្នោះក៏និយាយថា: "ទុគុណបុណ្យព្រះជាម្ចាស់ លោកមានបំរើដែលអាចធ្វើឲ្យទឹកនៅក្នុងក្អមខ្ញុំទៅជាមាសទាំងអស់" ថាដូច្នោះហើយគាត់យកក្អមៈទៅទង្គិចនឹងពួកអ្នកបំរើ ស្រាប់តែមាសហូរចេញមកគគុក ៗ ពួកបំរើនាំគ្នាស្រែកទ្រហឹងអឺងកងដណ្ដើមមាសគ្នា ៗ ព្រះរាជាទ្រង់បានឮស្នូរសំរូរំពងខ្ញៀវ ៗ ក៏មានព្រះបន្ទូលសួរថា: "សូរអ្វីលាន់ទ្រឹម៉្លេះ?" ៗ អ្នកបំរើទូលព្រះអង្គថា: "មានយាយម្នាក់ចូលមកដងទឹក ហើយពួកយើងក៏បានសួរគាត់ថា: យាយឯងមករកអ្វី ត្រូវការទឹកឬ?

គាត់នៅតែឈរហាលថ្ងៃ ប៉ុន្តែគាត់ជ្រមុជក្អមគាត់ទៅក្នុងល្ហូទឹកដែលគ្មានទឹកសោះ ហើយស្រាប់តែលើកឡើងមានឪណាពេញ រួចគាត់ដើរចេញបាត់ទៅហើយ គ្មានទរណាមួយដែលមិនយកឪណារបស់គាត់ទេ”ៗ ព្រះរាជាទ្រង់ព្រះសណ្ដាប់ដូច្នេះហើយក៏មានព្រះបន្ទូលថា: “ព្រះអើយ! បើប្រសិនជាអញបានឃើញគាត់ អញនឹងសូមឲ្យគាត់ប្រោសប្រណីឲ្យពរអញ ពីព្រោះគាត់ពោលសំដីពិត” នេះហើយជាហេតុដែលបង្កើតឡើងដោយមិនដឹងខ្លួន ៗ បំណែកឯយាយចាស់ បានត្រឡប់ទៅកាន់ទីលំនៅគាត់វិញ ៗ ព្រះអង្គម្ចាស់អាលីទ្រង់ទតយល់ហើយ ទ្រង់ស្ទុះមកទទួលហើយចាប់ដៃគាត់ ៗ ក៏ទូលទ្រង់ថា: “ខ្ញុំម្ចាស់បានប្រើឧបាយប្រវញ្ចន៍ បើប្រសិនជាឧបាយនេះប្រកបការទាំងអម្បាលម៉ាន នឹងបានសំរេចដូចសេចក្ដីប្រាថ្នាទាំងអស់ សូមទ្រង់កុំព្រួយព្រះហឫទ័យ” ៗ គាត់ទុកវេលាបីថ្ងៃឲ្យរំលងហួសទៅទៀត ៗ ដល់ថ្ងៃទីបួន គាត់យកឪណាដាក់ក្នុងក្អមគាត់ទៀត គាត់គ្របដោយកន្ទ្រើមួយ ហើយក៏ដើរកាត់មុខទ្វារព្រះរាជវាំងដូចមុន ៗ ពួកអ្នកបំរើស្ដេចលុះក្រឡេកឃើញគាត់ក៏រត់សំដៅទៅ ហើយចាប់ដៃគាត់ៗក៏ដើរចូលទៅជិតល្ហូទឹក ជ្រមុជក្អមទៅក្នុងទឹកហើយពោលថា: “ចូរអ្នកយកនូវអំណោយក្នុងពិភពលោកដែលប្រកបដោយអនន្តធម៌” ថាហើយគាត់ចាក់ឪណាក្រាលពេញកន្ទ្រើងនោះ ៗ ពួកអ្នកបំរើស្ទុះដណ្ដើមគ្នាប្រញាយ ថែមទាំងស្រែកលាន់

ទ្រហឹងផង ។ ព្រះរាជាទ្រង់ជ្រាបដោយមានគេទូលទ្រង់ៗ ត្រាស់បង្គាប់ថា: "នាំយាយនោះមកឲ្យអញ" កាលទ្រង់ទតយល់យាយចាស់មកដល់ ទ្រង់ស្ទុះទៅថើបដៃយាយចាស់នោះដោយគោរព ។ យាយចាស់ក៏ប្រដៅឲ្យទ្រង់ខ្ចាចនូវអំពើបាបអំពើនរក ហើយឲ្យប្រព្រឹត្តតាមផ្លូវធម៌ផង ។ កាលណោះ ព្រះរាជាទ្រង់មានព្រះបន្ទូលថា: "ខ្ញុំមានចិត្តត្រេកអរនឹងយាយក្រៃពេក ខ្ញុំមានចិត្តចង់ឲ្យយាយទៅលេងផ្ទះកូនស្រីខ្ញុំផង ប្រហែលជានាងចូលចិត្តទទួលពរយាយដែរមិនដឹង" ។ យាយចាស់ទូលតបថា: "តាមតែទ្រង់សព្វព្រះរាជហឫទ័យ" ។ ព្រះមហាក្សត្រក៏នាំយាយចាស់ចូលទៅក្នុងដំណាក់ព្រះនាង ។ ព្រះនាងលុះឃើញគាត់ទៅដល់ក៏ស្ទុះមកទទួលថើបដៃគាត់ដោយគោរព ហើយទ្រង់មានព្រះបន្ទូលថា: "លោកយាយ! ខ្ញុំចង់ឲ្យលោកយាយនៅសំរាក្នុងផ្ទះខ្ញុំក្នុងយប់នេះ ដើម្បីនឹងប្រស្រ័យគ្នាលេង ហើយនឹងឲ្យស័ព្ទសាធុការពរដល់ខ្ញុំផង" ។ យាយចាស់ឆ្លើយថា: "ខ្ញុំម្ចាស់នឹងនៅតាមព្រះរាជបំណងពុំបានទេ ព្រោះខ្ញុំម្ចាស់មានកូនស្រីមួយ ហើយគ្មាននរណានឹងមើលថែទាំផង" ។ ប៉ុន្តែព្រះនាងនៅតែចចេសថា: "ទុកជាយ៉ាងណាក៏ដោយ ត្រូវតែយាយនៅសំរាក្នុងផ្ទះខ្ញុំ" ។ យាយចាស់ក៏នៅជាមួយនឹងព្រះនាងអស់រាត្រីបីថ្ងៃគត់ ។ ក្នុងពេលនោះ បេះដូងនៃព្រះអង្គម្ចាស់អាលីហាក់ដូចជានៅលើរងើកភ្លើង ។

លុះដល់ថ្ងៃជាគំរប់ឬន ទ្រង់គាលីដែលមានព្រះទ័យបារម្ភណ៍នឹងបាត់យាយចាស់យូរពេក ក៏មានព្រះបន្ទូលថា: "មានតែព្រះជាម្ចាស់ទេ ដែលមានកំឡាំងព្រះហឫទ័យពូកែ តើមានហេតុអ្វីបានជាយាយចាស់បាត់សូន្យម្ល៉េះ?" ។

ចំណែកឯយាយចាស់គាត់ក៏ទូលព្រះនាងថា: "ព្រះនាងដ៏ប្រសើរ! ខ្ញុំម្ចាស់ចង់ត្រឡប់ទៅផ្ទះប្រាប់កូនឱ្យដឹងសិនកុំឱ្យព្រួយចិត្ត ហើយខ្ញុំម្ចាស់នឹងត្រឡប់មកវិញ បើត្រូវនៅ១ខែ ឬ២ខែក៏ខ្ញុំម្ចាស់លែងបារម្ភណ៍អ្វីទៀតឡើយ" ។ ព្រះនាងសួរបញ្ជាក់ថា: "យាយឯងប្រាកដជាមានកូនស្រីមែនឬ?" ។ យាយចាស់ទូលតបថា: "តើមនុស្សបែបខ្ញុំម្ចាស់នេះ ពេះនិយាយកុហកឬ? ខ្ញុំម្ចាស់មានកូនស្រីមួយដែលមានមុខល្អគ្មាននរណាដូច នាងរវល់តែគោរពព្រះអាទិទេពហើយមិនរវល់ដល់សត្វលោកទេ" ។ ព្រះនាងទ្រង់ព្រះសណ្ដាប់ហើយមានព្រះបន្ទូលទៀតថា: "ព្រះគុណអើយ! ខ្ញុំចង់ឱ្យនាងមកផ្ទះខ្ញុំ" ។ យាយចាស់ឆ្លើយថា: "គ្មានផ្លូវទេ ព្រះនាង!" ។

- ឱអ្នកម្ដាយអើយ! ល្អឯណោះម៉្លេះយ៉ាងដូចម្ដេចឱ្យតែនាងសុខចិត្តមក ។

- បើសិនជាខ្ញុំម្ចាស់និយាយបាន ខ្ញុំម្ចាស់នឹងនាំមកថ្វាយព្រះនាង ប៉ុន្តែទាល់តែព្រះនាងព្រមព្រះហឫទ័យកុំឱ្យនាងបើកមុខឱ្យសោះ ពីព្រោះតាំងតែព្រះជាម្ចាស់បានឱ្យជីវិតនាងមក នាងមិនដែលបើកមុខឱ្យនរណាឃើញទេ ។ ព្រះនាងមានព្រះបន្ទូលថា. "ខ្ញុំសុខចិត្ត" ។

យាយតាសក៏ក្រោកដើរចេញពីដំណាក់ព្រះនាង ហើយដើរដំរង់ទៅរកព្រះអង្គម្ចាស់អាលី ៗ មានព្រះហឫទ័យរីករាយពេក ដោយឃើញយាយតាសត្រឡប់មកវិញ ហើយមានព្រះបន្ទូលសួរថា: "សូមយាយនិយាយរឿងរ៉ាវដែលបានទៅនៅជាមួយនឹងព្រះនាង ប្រាប់ខ្ញុំផងយ៉ាងណាខ្លះ" ។ យាយតាសក៏និយាយរឿងរ៉ាវទូលទ្រង់សព្វគ្រប់ ហើយក៏យកសំលៀកបំពាក់ និងក្រមាទទូរធ្វើអំពីរោមចៀមមកបំពាក់ឲ្យទ្រង់ ហើយក៏នាំទ្រង់ទៅកាន់ដំណាក់ព្រះនាង ។ លុះអ្នកទាំងពីរដើរមកដល់ទ្វារព្រះបរមរាជវាំង ពួកអ្នកបំរើនិងពួកឆ្មាំទ្វារនាំគ្នាស្រែកទទួល ព្រមទាំងនាំគ្នាចេញត្រសងមកថើបដៃគាត់ដោយគោរពផង ។ បន្ទាប់មក គេប្រគល់គេហស្ថានមួយទុកឲ្យព្រះអង្គម្ចាស់អាលីស្រូតធម៌នៅពេលយប់ ។ យាយតាសប្រាប់ទៅពួកអ្នកបំរើទាំងប៉ុន្មានថា: "ខ្ញុំត្រូវទៅកន្លែងការនាធម៌ ព្រោះខ្ញុំក៏ដូចជាកូនខ្ញុំដែរ ដែលមិនអាចនឹងបោះបង់ព្រះធម៌ចោលបាន" ថាដូច្នេះហើយក៏ទៅកាន់ទីកន្លែងគាត់ទៅ ។

ចំណែកព្រះអង្គម្ចាស់អាលី ទ្រង់រវល់តែការនាធម៌តាំងតែពីព្រលឹមដល់ព្រលប់គ្មានសំរាកសោះ នៅពេលនោះគេយកអាហារនឹងនំផ្សេងៗមកថ្វាយទ្រង់ ប៉ុន្តែទ្រង់មិនព្រមទទួល ។ គេក៏សួរទ្រង់ថា: "តើអ្នកត្រូវការពិសាអ្វីវិញ?" ។ — នំបុ័ងធ្វើអំពីម្សៅនិងអំបិលគ្រាប់ ។ ពេលនោះព្រះនាងទ្រង់បែរទៅមានព្រះបន្ទូលនឹងនាងមាដិនា ជាស្នំឯក

ថា៖ "នេះគឺជាអនុគ្រោះនៃព្រះជាម្ចាស់ដ៏ក្រៃលែង" ហើយព្រះនាងក៏មានព្រះបន្ទូលទៀតថា៖ "ខ្ញុំចង់ឲ្យគាត់សង្កត់ខ្នងគាត់មកលើខ្នងខ្ញុំ ដើម្បីកុំឲ្យក្អែងនរកមកធាបធេះខ្ញុំបាន" បន្ទាប់មកព្រះនាងត្រាស់បង្គាប់ឲ្យគេនាំព្រះអង្គម្ចាស់អាលីទៅព្រះដំណាក់ព្រះនាងមួយរំពេច ។ ព្រះអង្គម្ចាស់អាលីសោយទំពាំងទឹងអម្បិលគ្រាប់ហើយក្រោកឡើងសូត្រធម៌ជាក្រោយបង្អស់មួងទៀត ។ នាងមាជិនាបើបដៃទ្រង់ ហើយក៏និយាយទូលទ្រង់ថា៖ "អ្នកស្រី! ខ្ញុំសូមអង្វរបិតុអ្នក ឲ្យអ្នកទៅសំពន្ធនៅដំណាក់ព្រះនាងយប់នេះ" ។ ទ្រង់អាលីមានបន្ទូលថា "ដូច្នេះក៏បាន" ទ្រង់ក្រោកឡើងហើយដើរចូលទៅក្នុងបន្ទប់ព្រះនាង ។ ឃើញស្តេចចូលទៅក៏ស្ទុះមកបើបដៃទ្រង់ដោយគោរព ។ ទ្រង់អាលីត្រាស់បង្គាប់ថា៖ "យកទៀននេះទៅឲ្យឆ្ងាយពីខ្ញុំទៅ" ក្រោយនោះទ្រង់ដោះសំលៀកបំពាក់ចូអំពីពេមចៀម ទុកតែអាវទ្រនាប់ ។ ព្រះនាងដោះអាវក្រៅចេញហើយក៏ចូលទៅ ព្រះនាងទឹងនាងមាជិនាដេកអមព្រះអង្គម្ចាស់ម្នាក់ ។ កាលណានាងមាជិនាក្រោកមុន បានមើលស្គាល់ជាស្តេចអាលីពិត ក៏និយាយទៅកាន់ទ្រង់ថា៖ "ឱ! ព្រះម្ចាស់ថ្លៃអើយ! ទ្រង់មិនគិតដល់ជីវិតទ្រង់ទេឬ បានជាហ៊ានយកជីវិតមករងដល់ទីនេះ? យាយតាស់មានជ័យជំនះ ក្នុងការប្រើឧបាយប្រវ័ញ្ចន៍" ។ បន្ទាប់មកនាងប្រស្រ័យជាមួយនឹងទ្រង់លុះដល់ព្រឹក ។ តមកទ្រង់អាលីតើន

ឡើងហើយការទានធម៌ហើយអង្គុយធ្វើព្រងើយ ។ នៅពេលនោះព្រះមហាក្សត្រជាព្រះវរបិតានៃព្រះនាង ទ្រង់យាងចូលទៅទាញដៃទ្រង់អាលីមកថើបដោយគោរព ។ ព្រះនាងក៏ទូលព្រះពាជាថា: "យើងបានបរិភោគជាមួយគ្នាទាំងអស់ពីល្ងាចម្សិលមិញ" ។ នាងមាជិនាដឹកដៃយាយជីក្មេងក្មួយនាំទៅឯផ្ទះសំណាក់ធម៌ នាងឆ្លៀតយកឱកាសស្ងាត់នោះទូលទ្រង់ថា: "ដល់ពេលសោយបើកាលណាគេយកក្រយាស្ងោយមកថ្វាយទ្រង់ សូមទ្រង់កុំសោយ ហើយទ្រង់ធ្វើពុតជាទ្រង់ប្រឈួនបេះដូង, បើកាលណាគេសួរទ្រង់ថាទ្រង់ចង់សោយអ្វី សូមទ្រង់ប្រាប់គេវិញថា: ចង់សោយក្រូបដូ នោះព្រះនាងមុខជានឹងប្រើបំរើឲ្យរត់រកទិញពេញទាំងក្រុងពុំខាន ហើយខ្ញុំម្ចាស់នឹងទូលតបព្រះនាងវិញថា: "ព្រះនាងរកបាន ដោយបង្គាប់ទៅពួកអារក្សបំរើព្រះនាងយកចំពៀនមកប្រើការទៅ"។ កាលណាខ្ញុំម្ចាស់ឃើញព្រះនាងយកចំពៀនពីកន្លែងណាហើយ ខ្ញុំម្ចាស់នឹងរកឧបាយលួចចំពៀនមកថ្វាយទ្រង់ឲ្យបានពុំខាន" ។ ព្រះអង្គម្ចាស់អាលីទ្រង់ព្រះសណ្ដាប់ហើយឆ្លើយថា: "បុះឧបាយអ្វីក៏ប្រសើរម្ល៉េះ!" ។

លុះដល់ពេលក្រយាស្ងោយល្ងាច យាយជីក្មេងក្មួយក៏ធ្វើតាមបណ្ដាំនាងមាជិនា ។ ព្រះនាងមានព្រះបន្ទូលសួរថា: "អ្នកត្រូវការអ្វី?" ។ យាយជីក្មេងក្មួយឆ្លើយថា: "ក្រូបដូ" ។ ព្រះនាងមានបន្ទូលថា:

"ទៅរកទិញនៅក្នុងទីក្រុងមក" ។ ពេលនោះនាងមាជិនា ក៏ឆ្លើយតបក្រាមថា: "បពិត្រព្រះនាងដ៏ប្រសើរ! ព្រះនាងអាចប្រើពួកអារក្សឲ្យទៅរកបាន ហេតុម្តេចបានជាព្រះនាងមិនប្រើឲ្យវាទៅយកក្រូចជូពីស្រុកអៀរ៉ាក់ យកមកជូនគាត់ទៅ" ។ ព្រះនាងតបថា: "ព្រះគុណអើយ! ឯងនិយាយនេះត្រូវមែន!" ត្រាស់ហើយព្រះនាងទ្រង់ក្រោកឈរឡើង ហើយទាញកូនសោមួយពីក្នុងអាវព្រះនាងប្រគល់ទៅឲ្យនាងមាជិនា ហើយមានព្រះបន្ទូលថា: "មាជិនាចូរឯងទៅបើកបន្ទប់តូចនោះ ហើយយកជណ្តើរមួយដែលមានកំពស់ ១០ ម៉ែត្រយកទៅដាក់លើទ្វារនៃមហាប្រាសាទ" ។ បន្ទាប់មក ព្រះនាងទ្រង់ចូលទៅយកថង់មួយហើយទាញយកកូនសោមួយ រួចព្រះនាងយកទៅបើកទ្វារបន្ទប់តូចមួយ ។ ព្រះនាងបើកប្រអប់មាសមួយហើយយកកូនប្រអប់តូច ១ ទៀតធ្វើអំពីក្អុកវិទ្ធមាស ហើយព្រះនាងយកបិះញៀនទិព្វនោះចេញមក ។ រួចព្រះនាងចុះជណ្តើរមកវិញទ្រង់ចូលទៅសំនឹកក្នុងបន្ទប់តូចមួយ ។ មួយស្របក់ក្រោយមកនាងមាជិនា កាន់បានក្រូចជូដែលមាននៅក្រុងអៀរ៉ាក់ ដើរចេញមក ។ នាងយកទៅដាក់នៅមុខព្រះភ័ក្ត្រព្រះអង្គម្ចាស់អាលីហើយទូលទ្រង់ដោយខ្សឹបៗថា: "ខ្ញុំម្ចាស់ស្គាល់កន្ទែងទុកបិញៀនហើយ" ។ ក្នុងខណ: ព្រះនាងមានព្រះបន្ទូលថា: "អញ្ជើញអ្នកពិសា!" ។ ព្រះអង្គម្ចាស់អាលី ថ្វាយបង្គំព្រះជាម្ចាស់ហើយ ទើបស្តេចសោយ ។

នាងស្នំក៏ថយចេញទៅ ព្រះអង្គម្ចាស់អាលីទ្រង់រំពៃព្រះនេត្រចាំមើលព្រះនាង ។ ក៏ទ្រង់យាងឡើងលើជណ្ដើរយកចិញ្ចៀនទៅទុក ហើយដោយព្រះនាងមានព្រះហឫទ័យរីករាយពេក ព្រះនាងទុកកូនសោនៅកន្លែងដដែល ហាក់ដូចជាព្រះជាម្ចាស់ដែលប្រកបដោយធន្ទះល្អមកជួយទ្រទ្រង់ ។ បន្ទាប់មក ព្រះនាងក៏ចេញមកមានព្រះបន្ទូលសួរទ្រង់អាលីថា: "ម្ដេចទៅអ្នក?" ។ - ព្រះនាងដ៏ឧត្តម! ខ្ញុំម្ចាស់ស្រួលទេ ប៉ុន្តែយប់នេះខ្ញុំម្ចាស់ចង់ទៅទទួលទានដំណេកឯផ្ទះខ្ញុំម្ចាស់ ដើម្បីកុំឲ្យមាននរណាទៅរំខាន" ។ ព្រះនាងក៏ចូលទៅផ្ទុំក្នុងបន្ទប់ព្រះនាងទៅ ។

នាងមាជិនាមកដល់ភ្លាម នាងឃើញជណ្ដើរ ឃើញកូនសោនៅនឹងទ្វារ ហើយក៏ទៅដាស់ព្រះអង្គម្ចាស់អាលីថា: "សូមទ្រង់តើនឡើង ការយើងបានសំរេចហើយ" ។ ព្រះអង្គម្ចាស់ទ្រង់តើនឡើងដោយមិនចង់ជឿដល់សិរីសួស្ដីផង ទ្រង់ស្រវាឡើងលើជណ្ដើរ បើកទ្វារទាញយកប្រអប់មាស ហើយយកចិញ្ចៀនមកស៊កនៅម្រាមព្រះហស្តទ្រង់ ទើបទ្រង់យាងមកទីកន្លែងទ្រង់វិញ ដោយមាននាងមាជិនាដើរតាមក្រោយ ។ នាងមាជិនាទូលទ្រង់ថា: "ព្រះអង្គម្ចាស់ក្សត្រាទ្រង់បានសន្យាថាមិនបោះបង់ចោលខ្ញុំម្ចាស់ទេ" ។ ទ្រង់អាលិឆ្លើយថា: "អញបានតាំងសន្យាថាមិនក្បត់ឯង ហើយនឹងការឯងយកធ្វើជាប្រពន្ធផង អញនឹងប្រគល់រាជសម្បត្តិឲ្យផង ដោយអញមានបំណងប្រាថ្នាតែចិញ្ចៀនប៉ុណ្ណោះ

នេះជាការណ៍ដែលអញអាចធ្វើបាន" ។ នាងសំស្ទុះទៅលុតជង្គង់ថើបព្រះហស្តទ្រង់ ៗ ក៏បង្គាប់នាងថា "មាជិនា! ចូរឯងដកខ្លួនចេញពីកន្លែងនេះសិនទៅ" ។ ក្រោយនោះព្រះអង្គម្ចាស់អាលីដាក់ចង្កៀងទៅលើដីហើយពោលថា: "ចេញមកម៉ៃមួន! ។ អារក្សបង្ហាញខ្លួនភ្លាម ឱនគំនាប់ទ្រង់ហើយមានវាចាថា: "ព្រះអង្គម្ចាស់! ខ្ញុំព្រះបង្គំជាខ្ញុំមានសេចក្តីលំបាកណាស់ កាលដែលព្រាត់ចេញពីទ្រង់ទៅ, ប៉ុន្តែទ្រង់ជួបស្រាប់ហើយឲ្យខ្ញុំព្រះបង្គំធ្វើម្តេច បើខ្ញុំព្រះបង្គំជាប់ចំចង្កៀងនេះហើយត្រូវតែស្តាប់បង្គាប់អ្នកណាដែលជាម្ចាស់ចង្កៀងនេះ" ។ ទ្រង់អាលីថ្លែងសេចក្តីអរគុណចំពោះអារក្ស ហើយទ្រង់បង្គាប់ថា: "នៅព្រឹកស្អែកនេះ ខ្ញុំចង់ឲ្យឯងរកអស្សុះកៅទេបាន ១ ពាន់នាក់ ដែលមានរូបភាពជាមនុស្សហើយសុទ្ធសឹងពាក់ស្រោមដែកថែមទាំងមានកាន់ដាវ កាន់ស្គរនិងកាន់ទង់ជ័យត្រៀបគ្នាផងមកឡោមទីក្រុងនេះ" ។ ម៉ៃមួនទទួលថា: "ព្រះករុណាថ្លៃពិសេស" ។ អារក្សក៏រលាយបាត់ទៅវិញ ។ មួយស្របក់ក្រោយមកអារក្សបង្ហាញខ្លួនឲ្យឃើញ ហើយទូលទ្រង់ថា: "ខ្ញុំបង្គំបានធ្វើតាមព្រះរាជបញ្ជាស្រេចអស់ហើយ" ។ ទ្រង់អាលីឆ្លើយថា: "សូមឲ្យព្រះដ៏មានបុណ្យជួយទ្រទ្រង់ឯង" ហើយទ្រង់មានបន្ទូលថែមទៀតថា: "ចូរឯងយកកូនសោនេះទៅដាក់ក្នុងថង់ព្រះនាងដោយកុំឲ្យព្រះនាងដឹងឮសោះ ដើម្បីកុំឲ្យនាងមាជិនាព្រួយបារម្ភ" ។

ម៉ែមួនក៏ធ្វើតាមបង្គាប់ ទ្រង់អាលីក្រោកឡើងដាក់ជណ្ដើរឲ្យដូចដើមវិញ ហើយក៏បង្គាប់ទៅម៉ែមួនទៀតថា: “ម៉ែមួន! អញចង់បានសេះខ្មៅមួយ មានពាក់កងកមាស ហើយនឹងសំពត់អាវដូចជាសំពត់អាវស្ដេច” ។ ម៉ែមួនយកមកថ្វាយទ្រង់ភ្លាម ។ ព្រះអង្គម្ចាស់អាលីឡើងគង់សេះហោះសំដៅទៅក្រៅក្រុង ហើយចុះទៅជិតពួកពលដែលឃើញហាក់ដូចជារបងដែកស្ងួត គ្រាន់តែសំរែកសេះធ្វើឲ្យញាប់ញ័រទាំងប្រថពី ធ្វើឲ្យទ្រង់អាលីមានសេចក្ដីរីករាយពន់ពេក ។

ព្រឹកស្អែកឡើង ពួកពលទាំងប៉ុន្មានដើរទន្ទ្រានចូលក្រុង គេឮសូរតែសំណូរធាប់ត្រែហើយនឹងការចលាចលកំរើកឡើងយ៉ាងសំបើម ។ ពួកពលរដ្ឋលុះឮសូរសន្ធឹកដូច្នេះនាំគ្នារត់ឡើងជិះសេះពល់រូប ។ ព្រះមហាក្សត្រក៏តើនឡើងដែរ ហើយទ្រង់យាងចូលទៅក្នុងបន្ទប់ព្រះរាជបុត្រី ដើម្បីនឹងប្រាប់ហេតុមហន្តរាយនោះ ។ ព្រះនាងទូលសួរព្រះវរបិតាថា: “ចុះទ័ពរបស់អ្នកណាអេះ?” ។ ព្រះមហាក្សត្រតបថា: បិតាមិនស្គាល់ទេ” ។ ព្រះនាងទូលព្រះមហាក្សត្រទៀតថា: “សូមព្រះវរបិតាកុំខ្លាច ខ្ញុំម្ចាស់នឹងទំលាយវាចេញអស់បាន” ថាហើយ ព្រះនាងយាងឡើងទៅលើប្រាង្គបើកទ្វាររកមើលចិញ្ចៀន ប៉ុន្តែពុំឃើញសោះ ព្រះនាងត្រឡប់ចុះមកវិញដោយមានសេចក្ដីតក់ស្លុតជាខ្លាំង ហើយក៏ត្រាស់សួរថា: “មាជីនាឯងដឹងចិញ្ចៀននៅឯណាឬទេ?” ។ នាង

សុំឆ្លើយថា: "ព្រះនាង! កាលដែលខ្ញុំម្ចាស់បែកចេញពីព្រះនាងទៅ ទ្រង់បានតាក់ស្មោទុកហើយតើ" ។ ព្រះនាងមានបន្ទូលទៀតថា: "ឯងនិយាយត្រូវហើយ ប៉ុន្តែឥឡូវនេះ អារក្សវាមកលួចយកទៅបាត់ទៅហើយ" ។ ព្រះនាងក៏ចូលទៅក្រាបបង្គំទូលព្រះវរបិតា ភ្លេចគិតសង្ស័យដល់យាយជីក្អែងក្អាយ ។

ព្រះមហាក្សត្រទ្រង់គង់សេះចេញទៅក្រៅក្រុង ពួកទ័ពទាំងពីរទំរៀបគ្នាជាជួរ ដើរឈមមុខទៅរកគ្នា ។ ព្រះរាជាក៏ហៅបំរើម្នាក់មកថា: "ឯងទៅមើលមើ! ពួកអស់នោះវាមានការអ្វី ហើយនឹងមើលឲ្យច្បាស់ តើទ័ពរបស់អ្នកណា ?" ។ បំរើលុះទៅដល់ជិតទ័ពបច្ចាមិត្ត ស្គាល់ច្បាស់ជាព្រះអង្គម្ចាស់អាលី ហើយរត់បាញ់ជើងត្រឡប់មកវិញ ។ ព្រះរាជាទតយល់ដូច្នោះ ត្រាស់សួរថា: "មានអ្វីដេញតាមក្រោយ បានជាឯងរត់លឿនម្ល៉េះ ?" ។ បំរើឆ្លើយថា: "ស្លាប់ហើយ ក្រាបទូលព្រះករុណាថ្លៃវិសេស ! ព្រះអង្គម្ចាស់អាលីដែលជាស្វាមីនៃព្រះរាជធិតា ព្រះអង្គ ទ្រង់លើកទ័ពមកច្រើនអនេកប្បការ ហើយប៉ងមកចាប់ព្រះរាជា នឹងព្រះរាជបុត្រីហើយ" ។ ព្រះរាជានឹងព្រះរាជបុត្រីទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ទ្រង់ព្រះកន្សែងជាខ្លាំង ។ ព្រះនាងមានបន្ទូលទាំងខ្សឹកខ្សួលថា: "វាគិតមកសងសឹកយើងទាល់តែបាន" ។ ព្រះរាជាប្រពលសន្ធញទៅរល់នឹងទ័ពបច្ចាមិត្ត ។ ទ័ពទាំងពីរពួក

ប្រយុទ្ធគ្នាយ៉ាងសំបើម ។ ប៉ុន្តែពួកជននៅក្រុងនោះធន់មិនបានដោយ ត្រូវពួកអារ័ក្សកាប់ផ្ដាច់ជាពីរក៏មាន កាប់ខ្ទេចខ្ទីក៏មាន ក៏រត់រាត់រាយ អស់ ។ ព្រះរាជាត្រឡប់ចូលមកក្នុងព្រះបរមរាជវាំងវិញ ហើយគង់ចាំ ជោគវាសនាជាមួយនឹងព្រះរាជបុត្រី ។

ម៉ៃមួននឹងអារ័ក្ស ១ រយនាក់ទៀតនាំគ្នាមកបានបំបាក់ទ្វារវាំងហើយ ចាប់ព្រះរាជានឹងព្រះរាជបុត្រីយកទៅថ្វាយទ្រង់អាលី ។ មានព្រះបន្ទូល ទៅព្រះនាងយ៉ាគូតាថា: « ស្រីចង្រៃ ! ម៉េចហ៊ានឃើញព្រះជាម្ចាស់ លោកផ្ដន្ទាហានទឹងឥតុកហានយ៉ាងណាបុះទេ » ។ បន្ទាប់មកទ្រង់ បង្គាប់ឲ្យអារ័ក្សម្នាក់ចាប់ព្រះនាងយ៉ាគូតា ទៅធ្វើទារុណកម្មយ៉ាងសំបើម ហើយទ្រង់កាត់ ១ ដាវហើយធ្វើឲ្យក្បាលហើរដាច់ចេញពីខ្លួន ឯចំណែក ព្រះមហាក្សត្រជាបិតាក៏បានទទួលនូវមរណភាពយ៉ាងនេះដែរ ។

ស្រេចហើយទ្រង់ប្រើឲ្យយករបស់យ៉ាងប្រសើរទៅជូនយាយចាស់ ដែលបានជួយគិតការទ្រង់ ហើយហៅនាងមាជិនា មកសួរថា: « មាជិនា ! ឯងចង់ឲ្យអញយកឯងធ្វើជាអ្វី ? » ។ នាងស្នំឆ្លើយថា « សូមទ្រង់ធ្វើតាម សេចក្ដីដែលខ្ញុំម្ចាស់បានទូលសុំព្រះអង្គ » ។ ទ្រង់អាលីបានព្រះស-ណ្ដាប់ហើយ ប្រើឲ្យហៅមនុស្សធ្វើជាសាក្សី នឹងកាឌីមកសរសេរកិច្ច សន្យាអាពាហ៍ពិពាហ៍មង្គលទ្រង់នឹងនាងមាជិនា ។ ព្រះអង្គម្ចាស់នឹងនាង ក៏រួមសេចក្ដីសុខជាមួយគ្នា ព្រមទាំងមានសេចក្ដីរីករាយជាពន្លឹកពន់ ។

ក្រោយមក ព្រះបាទអាលីមានព្រះឱង្ការហៅម៉ែមួនមកប្រាប់ថា៖ "អញចង់ឲ្យឯងទៅក្រាបទូលព្រះរាមអញទាំងពីរថា៖ អញបានសោយរាជសម្បត្តិនៅនគរនេះ" ។ ម៉ែមួនទទួលតាមព្រះរាជបញ្ជាហើយហោះឆ្ពោះតម្រង់នាំសេចក្ដីនោះទៅទូលព្រះរាមទ្រង់ទាំងពីរព្រះអង្គ ។ ព្រះរាមទាំងពីរក៏មានបន្ទូលផ្ដាំផ្ញើមកវិញថា៖ "ចូរឯងទៅគំនាប់នឹងថើបដៃទ្រង់ជំនួសយើងផង ហើយទូលទ្រង់ថា យើងសូមកុំឲ្យទ្រង់ភ្លេចយើងទាំងពីរឲ្យសោះ" ។ អារក្សម៉ែមួន ក៏ហោះត្រឡប់ទៅទូលព្រះបាទអាលីតាមពាក្យបណ្ដាំនៃព្រះរាមទាំងពីរវិញ ។

បន្ទាប់មកទៀត ព្រះបាទអាលីក៏ត្រាស់ប្រើបំរើឲ្យទៅអញ្ជើញតាចាស់ដែលបានឲ្យផ្ទះទ្រង់សំណាក់នឹងអ្នកលក់គ្រឿងក្រអូប ហើយទ្រង់សំដែងអាការគោរពនឹងរាប់អានដ៏ប្រសើរ ។ ព្រះបាទអាលីក៏នៅសោយរាជសម្បត្តិជាមួយនឹងនាងមាដិនា ដោយសួស្ដីដរាបដល់អស់ជីពជន្ម ។

ចប់ រឿងចិញ្ចៀនទិព្យ

# រឿងប៉ូល និងវីរ៍ស៊ីនី

## លោក ផេង-ជ្រីវ សាស្ត្រាចារ្យ នៅសាលាគរុវិជ្ជា ភ្នំពេញ

### ប្រែរៀបរៀង

(តចប់ តពីខ្សែលេខ ១០ មក)

---

កន្លែងនោះ នៅចំកណ្ដាលកោះ មានព្រៃព័ទ្ធជុំវិញ គេមើលសមុទ្រក៏មិនឃើញ កំពង់ផែល្វីក៏មិនឃើញ វិហារប៉ុំប្លើមុះក៏មិនឃើញ អ្វីដែលនាំឲ្យអាប៉ូលរលឹកនាងវីរ៍ស៊ីនី គឺគ្មានទាំងអស់ ។

នៅទីស្ថាននោះហើយដែលខ្ញុំនាំអាប៉ូលយកទៅទុក ៗ ខ្ញុំមិនហ៊ានឲ្យវានៅស្ងៀមឡើយ គឺឲ្យវាដើរជាមួយនឹងខ្ញុំ ហាលថ្ងៃ ហាលភ្លៀង ទាំងទីវាលព្រៃឥតឈប់ឈរ ខ្ញុំនាំវាធ្វើដូចជាវង្វេងក្នុងព្រៃ នាទីដីទើបនឹងភានថ្មី ក្នុងចំការទាំងឡាយ ដើម្បីបំភាន់គំនិតវា ដោយការនឿយហត់កាយខាងក្រៅ នឹងប្ដូរគំនិតឲ្យទៅជាគំនិតគិតពិចារណារក ព្រោះភ្លេចកន្លែងដែលយើងដើរនឹងបាត់ផ្លូវដែលមក ៗ តែត្រង់ព្រលឹងនៃសង្សារ ទោះទៅនៅទីណា គង់មិនភ្លេច: ស្នាមគំនូសនៃវត្ថុជាទីស្រឡាញ់ ៗ យប់នឹងថ្ងៃ ការស្ងប់ស្ងាត់នឹងសំឡេងអ្នកស្រុកទាំងឡាយ ទាំងពេលវេលាក៏ដោយដែលសម្រាប់បន្សាត់បង់ខ្វល់សេចក្ដីរលឹកគ្រប់យ៉ាង សភាវៈទាំងឡាយនេះ មិនអាចបំបែកចិត្តអាប៉ូលបាន ៗ សេចក្ដីខាងលើនេះ ប្រៀបដូចម្ជុលដែលគេយកទៅឲ្យប៉ះនឹងមេដែក ហើយទោះ

បីគេយកទៅទុកស្បៀមក៏វានៅតែញ័រ វិលរកមេដែកដែលសម្រាប់ទាញវាទៅ ។ កាលដែលយើងនៅក្នុងព្រៃ ហើយវង្វេងផ្លូវក្នុងភូមិ វិលវ៉ាំ ខ្ញុំសួរវាថា: "ឥឡូវនេះ តើយើងនឹងងាកទៅទិសខាងណាវិញ?" ។ វាបែរទៅខាងជើងហើយប្រាប់ខ្ញុំថា: "ទុះទន្ទុំយើង ចូរយើងត្រឡប់ទៅវិញ" ។

ដល់ឃើញឯចឹង ខ្ញុំគិតថា ឧបាយកលទាំងប៉ុន្មានដែលខ្ញុំយកមកប្រើ ដើម្បីបន្ទំវាឥតបានការ ។ ដូច្នេះ នៅសល់តែគម្រោះមួយគឺព្រលែង បំត្រង់ចំណង់វាតែម្ដង តែមិនដឹងជានឹងកើតការឬទេ ព្រោះទាល់ប្រាជ្ញហើយ ។

ខ្ញុំឆ្លើយទៅវិញថា: 'មែនហើយ! អើ! ក្ដុំហ្នឹងហើយដែលនាងកញ្ញា វីរស៊ីនី ធ្លាប់នៅពីដើម រូបនេះនែកូន! រូបដែលឯងបានឲ្យទៅនាង ហើយវេលានាងស្លាប់ទៅយើងឃើញពាក់ជាប់នៅនឹងខ្លួននាង" ។ ខ្ញុំបង្ហាញកូនរូបទៅវា គឺរូបហ្នឹងហើយដែលអាប៉ូលឲ្យទៅ វីរស៊ីនី នៅក្បែរកំពង់ទឹក ក្រោមដើមដូង ។ គ្រឡេកឃើញរូបនេះ វាញញឹមស្ងួត ។ វាទទួលយកប្រញាប់ប្រញាល់ ដោយដៃទាំងពីរ ញ័រញ័រ លើកដាក់ដល់មាត់ ។ ទ្រូងបុកផ្អក ៗ ទឹកភ្នែកខានហូរទៅជាធ្លាក់មក ។

ខ្ញុំប្រាប់ថា "នែកូន! ចូរអ្នកស្ដាប់ខ្ញុំជាមិត្របស់អ្នកទឹងនាង វីរស៊ីនី ហើយជាអ្នកយកចិត្តទុកដាក់ខំប្រឹងជួយពន្យល់ ទាំងការពារនឹងគ្រោះថ្នាក់ទាំងឡាយដែលបំរុងនឹងមានឡើងដល់ជីវិតអ្នក នាកណ្ដាលសេចក្ដី

ប្រាថ្នារកនូវវត្ថុដែលអ្នកត្រូវការស្ទើរតែជាប់ជាដរាប ។ បុះអ្នកស្រណោះ ស្រណោកអ្វីខ្លាំងម៉្លេះ? គឺជាទុក្ខផ្ទាល់ខ្លួនឬ ជាទុក្ខអំពី វិរសិទ្ធិ? គឺជាទុក្ខផ្ទាល់ខ្លួន! ប្រាកដមែនហើយ ទុក្ខហ្នឹងធំមែន ព្រោះអ្នកព្រាត់ពាកស្រីជាទីបេតី ជាស្រីគួរជាទស្រីទាំងពួង ។ នាងនោះស៊ូលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជាប្រយោជន៍ដល់អ្នក ហើយស៊ូលះបង់សេចក្ដីសុខឲ្យតែបានប្រទះនឹងរូបអ្នក គឺខ្លួនអ្នកដូចជារង្វាន់មួយគួរដល់ចិត្តធម៌របស់នាង ។ តើអ្នកឯងដឹងទេ វត្ថុណាដែលអ្នកត្រូវការបង់បាន សេចក្ដីសុខដ៏បរិសុទ្ធហើយត្រឡប់បណ្ដាលឲ្យកើតអណ្ដាតគឺសេចក្ដីទុក្ខកប់មិនអស់វិញ, ក៏គ្មានសុខទេ វែមទាំងប្រាសចាកសម្បត្តិផង ហើយចាប់តាំងពីបានគ្នាជាប្ដីប្រពន្ធវេលាណា អ្នកត្រូវធ្វើការយ៉ាងនឿយហត់ជាមួយគ្នា ។ នាងនោះត្រឡប់ខ្សោយកំឡាំងដោយការបង្អត់បង្អៀន តែមានចិត្តក្លាហានដោយសារមានទុក្ខញយៗ ហើយអ្នកតែងឃើញនាងនោះទ្រុឌទ្រោមទៅកល់ថៃ្ង មកពីខំជួយនឿយហត់លំបាកជាមួយគ្នា ។ កាលណាមានកូន សេចក្ដីទុក្ខរបស់នាងនិងអ្នករឹតតែចំរើនច្រើនឡើង ព្រោះលំបាករកចិញ្ចឹមតែគ្នាពីរនាក់ទាំងម្ដាយផង ទាំងកូនរេះតែកើតច្រើនឡើងផង ។

អ្នកឯងមុខជាឆ្លើយថា: « លោកហៅហ្វាយនឹងជួយទំនុកបំរុង » ។

អ្នកដឹងឬទេ នៅស្រុកចំណុះ អ្នកពជការផ្លាស់ប្ដូរជាធម្មតា អ៊ីអ្នកស្មានថាលោក ឬរដ្ឋណា ធ្វើការនៅទីនេះជានិច្ច? ចុះបើថ្ងៃក្រោយលោកចៅហ្វាយថ្មីត្រូវផ្លាស់មកគ្មានចិត្តធម៌ក្នុងខ្លួន, ហើយចុះ បើចង់បានឲ្យគេជួយទុកធុរៈ បន្តិចបន្តួច តើត្រូវធ្វើដូចម្ដេច មានតែតាំងឲ្យប្រពន្ធអ្នកទៅគំនាប់គាប់គួរនឹងគេ, . ចុះបើនាងនោះចិត្តទន់ពេក អ្នកឯងនឹងមិនកើតទុកទៀតហើយ ឬបើនាងចិត្តស្លូតត្រង់ អ្នកមុខជាត្រូវនៅតែក្រលំបាកជាដរាប! សប្បាយមែន បើប្រពន្ធអ្នកមានរូបល្អ ចិត្តប្រកបដោយធម៌ ហើយខ្លួនអ្នក លោកចៅហ្វាយមិនធ្វើទុកបុកម្នេញ គេជួយទំនុកបំរុងដោយល្អ ។

អ្នកមុខជាឆ្លើយមកទៀតថា: “ នៅសល់សេចក្ដីសុខម្យ៉ាង: មកពីខ្ញុំឈប់ត្រូវការចង់មានចង់បាន គ្រាន់តែទំនុកបំរុងវត្ថុជាទីស្រឡាញ់ដែលជាប់ជំពាក់ជាមួយគ្នា សមគួរដល់ចំណង់ក៏ គ្រាន់តែថ្នាក់ថ្នមលួងលោមវត្ថុនោះដោយការប្រឹងប្រែងញាប់ញ័រដៃជើង គ្រាន់តែធ្វើឲ្យវត្ថុនោះរីកពាយ ដោយចិត្តទៀយព្រួយនឹងបង្កើតចិត្តស្នេហា ដោយការទៀយលំបាកជួយគ្នាទៅវិញទៅមក ។ មែនពិត ចិត្តធម៌នឹងចិត្តស្នេហាកើតមកពីសេចក្ដីរីកពាយល្វឹងចត់ ។ ឥឡូវធ្វើម៉េច នាងបាត់បង់ទៅហើយ នៅសល់តែម្ដាយនាងនឹងម្ដាយអ្នក ដែលអ្នកនឹងជូនដំណើរទៅកាន់លោកខាងមុខប្រកបដោយសេចក្ដីទុក្ខប្រៀបពុំបាន ។ ចូរអ្នកឯង

ខំថែរក្សាអ្នកដ៏មានគុណទាំងពីរឲ្យបានសុខដូចជាលោកធ្វើឲ្យអ្នកបានសុខមកយូរហើយ ។ អំពើល្អជាសុខម្យ៉ាងកើតមកពីចិត្តធម៌ ។ គ្មានសេចក្ដីសុខណាទៀតនឹងធំជាងសេចក្ដីសុខនោះឡើយ នៅលើផែនដី ។ គំនិតប្រាថ្នាចង់បានសេចក្ដីរីករាយ កើតមកពីការសម្រាក សេចក្ដីរីករាយដ៏ក្រៃលែង សម្បត្តិស្ដុកស្ដម្ភ ចំរើនដោយយសស័ក្ដិ របស់ទាំងនេះមិនមែនកើតសម្រាប់មនុស្សសាមញ្ញជាអ្នកដំណើរដ៏ខ្សត់ខ្សោយទេ ។ ឯងឃើញឬទេ គ្រាន់តែឈានជំហានមួយសោះសំដៅរកធនធានប៉ុណ្ណោះ ព្រានយើងជ្រុលជ្រែករមៀលជាំតិតជាំតូង ធ្លាក់ពីរណ្ដៅមួយទៅរណ្ដៅមួយ ។ អីខ្ញុំថាដូច្នេះ អ្នកឯងយល់ទាស់ឬ? រឿងនេះពិតណាស់ ឃើញឬទេ អ្នកណាមិនស្មានថាដំណើរនាងកញ្ញាវីរស៊ីនី បានដល់នៅទីបំផុត ត្រូវបានសេចក្ដីសុខស្រួលទាំងរូបនាង ទាំងរូបអ្នក, ម្ដាយមីងចាស់ទាំងមានទ្រព្យច្រើនហៅទៅ ពាក្យពន្យល់របស់លោកចៅហ្វាយដ៏ស្លូតត្រង់ ពាក្យឲ្យពរសព្វសាធុការនៃអ្នកស្រុកទាំងឡាយកង្កោះ លោកសង្ឃមួយអង្គ ជួយនិយាយបន្ទំនឹងប្រើអំណាចព្រះជាម្ចាស់ទៀត ឲ្យតែនាងបានទៅ ព្រោះចង់ឲ្យនាងសុខស្រួល ប៉ុនជាបបួលគ្នាបញ្ជូននាងឲ្យដល់នូវសេចក្ដីទុក្ខធំបំផុតកែមិនឡើងទៅវិញ ។ ហេតុដូច្នេះ យើងពល់រូបបាននូវសេចក្ដីវិនាស ព្រោះតែភ័ន្តដោយការប្រយ័ត្នខ្លាំងពេកនៃនាយចៅហ្វាយជាអ្នកត្រួតត្រាក៏មាន ។ បើឯចិនត្រូវ

តែកុំជឿឲ្យសោះ ឲ្យអ្នកទាំងនោះទឹង កុំទុកចិត្តដល់សំដី សេចក្ដីសង្ឃឹមនៃលោកទាំងមូល ព្រោះប្រែទកុហក បំភ័ន្ត ៗ ប៉ុន្តែបើនិយាយដោយផ្ដាច់ខាត មនុស្សទាំងឡាយដែលយើងឃើញនៅធ្វើការរកស៊ីសព្វថ្ងៃក្នុងកោះនេះក្ដី មនុស្សទាំងឡាយដែលចេញទៅស្វែងសម្បត្តិឯប្រទេសក្រៅក្ដី ឬអ្នកណាមួយមិនចេញពីទឹកដីខ្លួន នៅចំតែធ្វើការងាររក្នុងប្រទេស-ខ្លួនក្ដី មិនមានអ្នកណាមួយចង់ឲ្យវិនាស ឃ្លាតចាកវត្ថុដ៏ថ្លៃថ្លារបស់ខ្លួនឡើយ គឺបុណ្យយសសក្ដិ ទ្រព្យសម្បត្តិប្រពន្ធកូនទឹងមិត្តសំឡាញ់ ៗ ចំណែកអ្នក ៗ មិនត្រូវចិត្តឡើយ ៗ ចិត្តនៅកំឡោះ ឈាមករ ដូចផ្កាកំពុងរីក មានសេចក្ដីស្លូតត្រង់ល្អព្រមទាំងមានការប្រយ័ត្ន កាន់របៀបអ្នកនេះ ៗ មានតែសេចក្ដីយល់របស់អ្នកទេ ទើបត្រូវតាមច្បាប់ ព្រោះជាយោបល់ដ៏បរិសុទ្ធ តាមធម្មតា វៀរចាកប្រយោជន៍ផ្ទាល់ខ្លួន ហើយចិត្តអ្នកដែលមានចំពោះនាងនារី វិរ៉ស៊ុទី ជាចិត្តឯក គួរកោតក្រែង រកវត្ថុអ្វីយកមកថ្លឹងឲ្យស្មើពុំបាន ៗ វិរ៉ស៊ុទី ដែលវិនាសទៅ មិនគឺមកពីសេចក្ដីប្រហែសធ្វេសនៃអ្នកក៏ទេ មកពីសេចក្ដីកំណាញ់នៃអ្នកក៏ទេ មកពីចិត្តអ្នកគិតខុសក៏ទេ នេះគឺមកពីព្រះជាម្ចាស់ទេតើ ព្រោះព្រះអង្គបណ្ដាលចិត្តអ្នកដទៃ ឲ្យមានចំណង់ដូច្នេះ ដើម្បីដកហូតវត្ថុជាទីបេតីពីអ្នក ព្រះអង្គដែលអ្នកគោរពពលថ្ងៃ ទ្រង់ជ្រាបច្បាស់នូវរបស់ដែលសមគួរដល់គាតនៃអ្នក បើដូច្នេះ អ្នកមិនត្រូវមានវិប្បដិសារីឡើយ អំពីរឿងនេះ ៗ

សេចក្ដីប៉ុណ្ណោះហើយ ដែលអ្នកគួរយកទៅទូន្មានចិត្តថ្នាំងថ្នាក់របស់អ្នក ខ្ញុំមិនគួរនឹងនិយាយឡើយ ។ នាងវីស៊ុន មានសេចក្ដីទុក្ខរហូតដល់ស្លាប់ខ្លួន រហូតដល់ឥឡូវនេះទៀត អ៊ីឯងនៅស្រណោះស្ដាយ ។ នាងដែលទទួលអកុសលកម្មនេះ គឺជាអំពើមានមកសម្រាប់ជាតិ សម្រាប់លំអទាំងឡាយរហូតដល់វដ្ដទាំងមូល ។ ជីវិតរបស់សត្វព្រមទាំងសេចក្ដីប្រាថ្នា តែងចំរើនខ្ពស់ទៅលើដូចជាប៉មតូចមួយដែលមានកំពូលចុងបំផុតគឺសេចក្ដីស្លាប់ ។ អ្នកណាដែលកើត មានទោសត្រូវស្លាប់ទៅវិញ ។ នាងនេះចំជាមានសំណាងល្អហើយស្រួលខ្លួនផង ដែលបានស្រាយចំណងរួចចេញពីជីវិតមុនម្ដាយនាង មុនម្ដាយអ្នក មុនអ្នក គឺថានាងនេះមិនត្រូវស្លាប់ច្រើនដងមុនការស្លាប់ជាបរិយោសាន ។

នែកូន ! មរណភាពជាសម្បត្តិរបស់សត្វទាំងឡាយក្នុងលោក ។ ជាក្រិតដ៏ងងឹតរបស់ព្រះអាទិត្យ ដែលមនុស្សលោកមានចិត្តញាប់ញ័រមិនឈប់ឈរអំពីជីវិត ។ ជម្ងឺរោគាព្យាធិ សេចក្ដីទុក្ខ សេចក្ដីព្រួយ សេចក្ដីភ័យទាំងឡាយដែលញុំាងសត្វលោកឲ្យរំភើបជានិច្ច តែងតែទៅសម្រាកក្នុងពោះនៃសេចក្ដីស្លាប់ ។ ចូរឯងពិនិត្យមើល មនុស្សណាដែលដូចជាបានសុខស្រួលគ្រាន់បើជាងគេ អ្នកនឹងឃើញសេចក្ដីសុខនោះមានដំឡៃក្រៃពេក គឺការរាប់អាននៃជនផងទាំងពួង បានមកដោយការនឿយហត់ក្រៀវក្រាងយ៉ាងច្រើន ទ្រព្យបានមកដោយការទំ

ប្រឹងខំរកភាល់តែស្គមខ្លួន សេចក្ដីរីករាយដ៏ក្រៃដើម្បីឲ្យជាទីពេញចិត្ត ប្រពន្ធ បានមកដោយការធ្វើមិនគិតខ្លួនប្រាណជានិច្ចកាលថ្ងៃ ហើយ លុះដល់ទីបំផុតនៃកិច្ចដូចបានពោលខាងលើ ដែលខ្លួនខំប្រឹងដើម្បីជាប្រយោជន៍អ្នកដទៃ មនុស្សនោះច្រើនតែចួបប្រទះតែនឹងបាបមិត្រ នឹងញាតិអកតញ្ញូនៅជុំវិញ ៗ នាងបានសុខស្រួលជាមួយនឹងអ្នក ដោយអំណាចបុណ្យព្រះជាម្ចាស់នៅឆ្ងាយពីយើង ដោយសារគុណនៃចិត្តធម៌ ហើយក្នុងពេលដែលយើងមានគ្រោះថ្នាក់យ៉ាងធំជាទីបំផុត យើងក៏គង់ឃើញនាងនៅតែសុខស្រួលដដែល ទោះបីនាងក្រឡេកមើលអ្នកកោះតាំងមូលដែលទុក្ខព្រួយដោយសារតែរូបនាង ឬមើលចំមកអ្នកដែលបេះតែស្ទុះចុះស្ទុះឡើង ដោយចិត្តក្លាហានឥតខ្លាចស្លាប់ដើម្បីនឹងទៅជួយសង្គ្រោះនាង នាងក៏គង់តាំងចិត្តជាកល្យាណមិត្តដ៏ថ្លៃថ្លាដល់យើងទាំងអស់គ្នាឥតរើសមុខ ៗ នាងខំប្រឹងយកសេចក្ដីស្លូតត្រង់ពីដើមមកទប់ទល់នឹងអនាគតកិច្ចប្រកបដោយទុក្ខ ហើយនាងបានទទួលរង្វាន់ពីព្រះ-ជាម្ចាស់ដែលទុកសម្រាប់ឲ្យចិត្តធម៌ គឺចិត្តក្លាហានយ៉ាងឆ្នើមនៅចំពោះមុខនៃគ្រោះថ្នាក់ ៗ នាងទទួលយកនូវសេចក្ដីស្លាប់ដោយមុខស្រស់ញញឹម ៗ

. . . . . . . . . . . . . . . . . . . . . . . . . . . . .

សេចក្ដីព្រឺព្រួចក្នុងចិត្តខ្លាំងពេក នាំឲ្យខ្ញុំឈប់ពន្យល់តែត្រឹមប៉ុណ្ណឹង ៗ ចំណែកអាប៉ូល លោសំឡឹងចំខ្ញុំ ក្អកក្រឡែតហើយ

ស្រែកថា: "នាងបែកបានទៅហើយ! នាងបាត់បង់ទៅហើយ!" រូបដោយអំណាចអស់កំឡាំងមកយូរហើយ រកស្រែកតទៅទៀតពុំរួច ក៏បាត់មាត់ឈឹងដូចគេសន្ទប់ ។

លុះត្រឡប់បើកភ្នែកឡើងវិញ ក៏និយាយថា: "បើសេចក្ដីស្លាប់ជាសម្បត្តិមួយ ហើយនាង វីរស៊ីនី ជាស្រីសុខស្រួល ខ្ញុំក៏បង់ស្លាប់ដែរ ដើម្បីនឹងទៅជួបនាងទៀត" ។ មើលទៅ គ្រឿងសាងទាំងប៉ុន្មានដែលខ្ញុំនាំយកមកអធិប្បាយដើម្បីលួងលោម ឃើញថាត្រឡប់ជាធ្វើឲ្យការងររឹតតែកើតទុក្ខឡើងទៀត ។ ខ្ញុំឧបមាដូចជាបុគ្គលម្នាក់បង់ស្រង់សំឡាញ់ម្នាក់លង់ទឹកកណ្ដាលទន្លេដែលមិនចង់ហែល ។ នេះគឺសេចក្ដីទុក្ខពន្ទុបក៏ ។ សេចក្ដីទុក្ខទាំងឡាយនៃជនក្នុងបឋមវ័យ ជាបច្ច័យឲ្យបានស្រួលទៅក្នុងវ័យទាំងឡាយខាងចុង តែអាប៉ូល មិនយល់ដូច្នោះសោះ ។

ខ្ញុំនាំការត្រឡប់មកផ្ទះវិញ ។ គេឃើញម្ដាយការនឹងនាង ឡាតួរ បេះតែស្រងូតស្រងាត់ហេវទៅ ៗ ។ នាង ម៉ារគីរីត មើលទៅ ដូចជាធ្ងន់ជាងគេ ។ ចរិតទាំងឡាយដំហើសការងារ កាលមានទុក្ខបន្តិចបន្តួចមិនធ្វើជាដឹង ដល់ប៉ះលើទុក្ខព្រួយយ៉ាងធំ ទប់ក្រែមបានណាស់ ។

នាងនេះ មានការបានឹងខ្ញុំថា: "ឱ! មាអើយ! យប់មិញ ខ្ញុំយល់សប្តិឃើញនាង វីរស៊ីនី ស្លៀកសពាក់ស ឈរនៅនាកណ្ដាលផ្កាដំឈូយឈូបក្នុងសួនច្បារ ។ នាងមានការបាមកកាន់ខ្ញុំថា . នាងបានសេចក្ដី

សុខស្រួលគួរសមណាស់ ។ រួចនាងដើរចូលទៅជិត អាប៉ូល សើច ញឹមៗ ហើយចាប់លើកកូនខ្ញុំទៅជាមួយនឹងនាងទៅ ។ ដល់ខ្ញុំខំប្រឹង ទាញកូនខ្ញុំទុក ដូចជាខ្លួនខ្ញុំហ្នឹងក៏អណ្តែតផុតជើងពីដីដែរ ហោះទៅតាម ក្រោយអាប៉ូល ខ្ញុំសប្បាយឥតឧបមា ។ វេលាដែលខ្ញុំរៀបនឹងលា សំឡាញ់ស្រីខ្ញុំ ស្រាប់តែឃើញនាងព្រមទាំង ឌូម៉ាំង នឹង ម៉ារី ហោះ តាមក្រោយខ្ញុំមកទៀត ។ ហើយរឿងនេះគួរអស្ចារ្យណាស់ គឺកង យប់ដដែលនាង ឡាគួរ ក៏យល់សប្តិឃើញដូចខ្ញុំដែរ „ ។

ខ្ញុំឆ្លើយតបថា: “ នៃនាងសំឡាញ់! ខ្ញុំយល់ថារបស់អ្វីដែលមាន មកកងលោក សុទ្ធតែព្រះអាទិទេពបើកអំណាចឲ្យមកទាំងអស់ ។ ចួនកាលយល់សប្តិហ្នឹងទៀងដែរ ” ។

នាង ឡាគួរ ក៏បាននិយាយប្រាប់ខ្ញុំនូវហេតុយល់សប្តិដែលមានទំនង ដូចគ្នា នឹងនាង ម៉ារគីរីត ហើយកងរាត្រីតែមួយ ។ ខ្ញុំមិនទាន់បានសំ- គាល់អំពីការជឿផ្តេសផ្តាសកងរូបនាងទាំងពីរផង ស្រាប់លោមកប្រទះ នឹងយល់សប្តិស្របគ្នាដូច្នេះ ហើយខ្ញុំយល់ដោយឥតសង្ស័យថាប្រាកដ ជានឹងឃើញហេតុគេទអ្វីមួយ យ៉ាងទាន់ហាននឹងក្លែកជាមិនខាន ។ មនុស្ស ទាំងឡាយលើផែនដីតែងជឿដូច្នេះដែរ ថាយល់សប្តិ ចួនកាលទៀង ប្រាកដណាស់ ។ អ្នកប្រាជ្ញទាំងឡាយពីសម័យបុរាណ ដូចជា: អាឡេក្សង់ (Alexandre) សេសារ (César) កាតុន (Caton) នឹងព្រះទុ

(Brutus មានបញ្ញាមិនអន់ប៉ុន្មាន គង់ជឿថាយល់សប្តិមានទៀងខ្លះដែរ ៗ រឿងខាងសម័យបូរាណនឹងរឿងខាងសម័យបច្ចុប្បន្ន មានថ្លែងជាឧទាហរណ៍រាប់មិនអស់ ពីយល់សប្តិដែលពិត ៗ ចំណែកខ្ញុំត្រូវការតែខាងទំលាប់របស់ខ្ញុំ ខ្ញុំបានដឹងជាច្រើនលើកមកហើយដែរ ថាយល់សប្តិជាបុព្វនិមិត្ត ដូចជាប្រាជ្ញារបស់យើងដែលឈ្វេងយល់ការអ្វីមួយឯចឹងដែរមុននឹងចាប់ធ្វើ ៗ

រឿងយល់សប្តិរបស់ស្ត្រីជាសំឡាញ់ខ្ញុំចំជាត្រូវមែន ៗ មិនយូរប៉ុន្មាន បានប្រមាណជាពីរខែ អាប៉ូល ទេះតែហៅគេនាង វីស៊ុទី ក៏មានជម្ងឺឈឺស្លាប់ទៅ ៗ នាង ម៉ារគីរីត ស្លាប់ក្រោយ អាប៉ូល ប្រាំបីថ្ងៃ ៗ មុននឹងអនិច្ចកម្ម នាងមានសេចក្តីសប្បាយរីករាយក្នុងចិត្ត ព្រោះនាងមានធម៌ក្នុងខ្លួន ហើយបានលា បានផ្តាំនាង ឡាគួរ ដោយមធុរវាចា ថាចាំយើងនឹងទៅជួបគ្នាឯស្ថានលើឯណោះ ជាស្ថានមិនបេះព្រាត់គ្នា ៗ នាងប្រាប់ទៀតថា: "មរណភាព ជាសម្បត្តិមួយធំជាងសម្បត្តិដទៃទាំងអស់ តែត្រូវចង់បានគប់គ្នា ៗ ដ្បិតថាការរស់នៅជាទោស ត្រូវប្រាថ្នាការស្លាប់វិញ ព្រោះការរស់នៅជាសេចក្តីព្រួយ ជាទុក្ខ ជាសោកជារោគ ជាភ័យ ជាគ្រោះថ្នាក់ដូច្នេះជាដើម បើឯចឹងត្រូវធ្វើរាំឲ្យខ្ញុំ" ។

ពជការជួយចិញ្ចឹម ទំនុកបំរុង ឱម៉ាំង និង ម៉ារី ដ្បិតចាស់ពេក ធ្វើការអ្វីមិនកើត ៗ មិនយូរប៉ុន្មាន ប្តីប្រពន្ធទាំងពីរក៏បែកស្ថានទៅដែរ ៗ

ឆ្កែមួយឈ្មោះ ហ្វ៊ីដែល ក៏ស្លាប់ស្របបាលគ្មានឹងម្ចាស់វាដែរ ៗ

ខ្ញុំនាំនាង ឡាតួរ ទៅនៅជាមួយនឹងខ្ញុំ ៗ ស្រីនេះបេះដូងខ្លួនឲ្យនឹងប៉ុនទៅកណ្ដាលនៃសេចក្ដីវិនាសដ៏ធំ ដោយចិត្តក្លាហាន ស្មើរតែមិនគួរជឿ ៗ នាងបានលួងលោមប្រដែប្រដៅខ្លួនាន អាប៉ូល ទីង នាង ម៉ារគីរីត រហូតដល់ពេលជាទីបំផុត ដូចជានាងគ្មានទុកផ្ដាល់ខ្លួនសោះ មានតែទុក្ខរបស់អ្នកដទៃ ៗ លុះអាប៉ូល ទីង ម៉ារគីរីត បាត់បង់ទៅ នាងនិយាយរឿងជនទាំងពីរប្រាប់ខ្ញុំរាល់ថ្ងៃ ដូចគ្រាន់តែជាមនុស្សព្រាប់អានគ្នានៅជិតខាង មិនជាប់ចិត្តប៉ុន្មាន ៗ ប៉ុន្តែបានមួយខែក្រោយមក នាងក៏ផ្ដើមរណកាលទៅដែរ ៗ ចំណែកម្ដាយមីងនៅឯប្រទេសបារាំង ដែលជាស្រីចិត្តអាក្រក់ ក៏ផ្ដើមរណកាលខាងក្រោយដែលបានបញ្ជូននាងវ៉ាស៊ីន មក ៗ មុននឹងស្លាប់ នាងនោះ លំបាកមើលណាស់ រញាក់រញ៉ីរ មិនដឹងយកទ្រព្យទៅផ្ញើឲ្យជនណា ណាមួយស្ដាយទ្រព្យ ហើយមានតែបងប្អូនសាច់ញាតិដែលគាត់ស្អប់ ម្ល៉ោះហើយក៏កើតចលា-ចលក្នុងចិត្តគាត់អម្ល៉េះទេ រៀបស្លាប់ ៗ

អាប៉ូល គេយកទៅកប់ក្បែរគុម្ពឬស្សី ជិតខ្មោចនាង វ៉ាស៊ីន ជាគូសង្សាររបស់វា ហើយនៅពីខាងក្រៅ គេកប់ខ្មោចម្ដាយវាទាំងពីរនឹងឈ្មលពីរនាក់ប្ដីនឹងប្រពន្ធ ៗ គ្មានអ្នកណា យកផែនថ្មទៅដាក់ពីលើផ្នូរហើយចារឹកដាក់ឈ្មោះទេ ៗ ប៉ុន្តែអំណាចនៃអំពើជាកុសលរបស់គេ តែងមាននៅក្នុងដួងវិញ្ញាណនៃមនុស្សគ្រប់គ្នា មិនចេះរលប់រលាយឡើយ ៗ ចប់

# បុណ្យឈាបនកិច្ចសពឧបាសិកាវ៉ុត

## ព្រះគ្រូសង្ឃសត្ថា បុណ្យ-សម្ភាជ រៀបរៀង

---

កាលនៅថ្ងៃសុក្រទី ១១ ធ្នូ ព. ស. ២៤៩៦ គ. ស. ១៩៥៣ ក្នុងវត្តទេពធីតារាម ក្រុងកំពង់ឆ្នាំង មានធ្វើពិធីឈាបនកិច្ចសពឧបាសិកាវ៉ុត ជាញោមរបស់ព្រះបាឡាត់បទុមវង្ស ពុធ-កេត បាឡាត់គណខេត្តកំពង់ឆ្នាំង ។

ក្នុងឱកាសបុណ្យឈាបនកិច្ចនោះ សម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈមហានិកាយ បាននិមន្តទៅជាអធិបតីព្រមទាំងសំដែងធម៌ទេសនា ។ កាលសម្តេចបាននិមន្តទៅដល់វត្តទេពធីតារាម នៅវេលាម៉ោងប្រាំមួយដប់ប្រាំនាទីរសៀល, ពួកពុទ្ធបរិស័ទជាច្រើនទាំងកងជីវពល, កងនារីក្លាហាន ព្រមទាំងអ្នករាជការទាំងឡាយ មានឯកឧត្តមលីគិម-ឃុត ចៅហ្វាយខេត្តកំពង់ឆ្នាំងជាប្រមុខ បានមកឈររង់ចាំទទួល ដើម្បីធ្វើគារវៈចំពោះសម្តេច ។ សម្តេចព្រះមហាសុមេធាធិបតី បាននិមន្តឡើងលើវេទិកា ដែលគេរៀបចំទុកប្រគេន ហើយមានថេរដីកាបដិសណ្ឋារកិច្ចតបចំពោះពួកពុទ្ធមាមកជនទាំងឡាយ មានឯកឧត្តមលីគិម-ឃុត ជាប្រធាន អស់កាលដ៏គួរ, លុះសម្តេចបានថ្លែងសេចក្តីចប់ហើយ មានឧបាសកម្នាក់ជាតំណាងបានរៀបរាប់អំពីជីវប្រវត្តិឧបាសិកាវ៉ុត ដែលទើបនឹងទទួលមរណភាពនោះ ដូចមានសេចក្តីជាសង្ខេបតទៅនេះ:

ឧបាសិការុត កើតនៅថ្ងៃសុក្រ ៧កើតខែមិគសិរ ឆ្នាំម្សាញ់ឯកស័ក ព.ស. ២៤១៥ នៅភូមិកណ្តាល ឃុំកំពង់ឆ្នាំង (ស្រុករលាប្អៀរ) (កំពង់ឆ្នាំង) ។ល។ ឧបាសិកានេះ លុះដល់ជន្មាយុគំរប់ ៨១ ឆ្នាំ ក៏មានជរាពាធចូលមកយាយីតាមធម្មតារបស់សត្វលោក, ព្រះបាឡាត់បទុមវង្ស នាមពុធ-កេត និងបុត្តធីតាព្រមទាំងញាតិមិត្រសាច់សាលោហិតដ៏ច្រើន បាននាំគ្នាចំបីបាច់ថែរក្សាព្យាបាលពេលនោះ ដោយថ្នាំឱសថផ្សេងៗ ក៏នៅតែមិនបានស្រាកស្រាន្តសោះ, រោគចេះតែមានកម្លាំងឡើង នាំឲ្យឧបាសិការុតមានឆិន្នាហារ (ដាច់អាហារ) អស់រយៈកាល ១ ខែ, លុះដល់មកថ្ងៃចន្ទ ២កើតខែមិគសិរឆ្នាំម្សាញ់បញ្ចស័ក ព.ស. ២៤៩៦ ឧបាសិការុតមិនអាចនឹងបន្តជីវិតភាពបាន ក៏ធ្វើកាលកិរិយាក្នុងជន្មាយុគំរប់ ៨១ ឆ្នាំ រំលងខ្លួនទៅកាន់បរលោកនាយ នៅវេលាម៉ោង១ដប់នាទីយប់ ចំពោះព្រះភក្ត្រព្រះសង្ឃក្នុងវត្តទេពធីតារាមនោះ ។

ចំណែកព្រះសង្ឃព្រមទាំងបុត្តធីតាញាតិមិត្រជិតឆ្ងាយ ដែលធ្លាប់ស្គាល់រាប់អានគាត់នោះ ក៏មានសេចក្តីអាឡោះអាល័យសោកស្តាយជាទីបំផុត, តែធ្វើម្តេចមច្ចុសង្គ្រាមគឺជាសង្គ្រាមសម្រាប់ព្រាត់មនុស្សសត្វឲ្យផ្តាច់ជីវិតសង្ខារ មិនដែលទទួលអង្វររបស់មនុស្សសត្វណាមួយឡើយ ។

លុះចប់ជីវប្រវត្តិនេះហើយ ព្រះបាឡាត់បទុមវង្ស បានថ្លែងអំណរគុណចំពោះពុទ្ធមាមកជនទាំងឡាយ, ចំពោះអ្នករាជការក្នុងខេត្តដែលមាន

ឯកឧត្តមលីគិម-យុត ជាប្រធានទទឹកផងដីពេល, កងនាវិកាហាន ដូចមានសេចក្ដីតទៅនេះ ៖

ខ្ញុំព្រះករុណា អាត្មាភាពសូមថ្លែងអំណរគុណដ៏លើសលុប ចំពោះព្រះភិក្ខុសង្ឃគង់ខេត្តនេះ ដែលមានព្រះតេជព្រះគុណព្រះធម្មវង្សាធិបតី មេគណជាប្រធាន និងអស់លោកពុទ្ធមាមកជនទាំងឡាយមានឯកឧត្តមជាដើម ដែលបាននិមន្តបានអញ្ជើញមកធ្វើការកិច្ចចំពោះសម្តេចផង ជាកិត្តិយសក្នុងឱកាសបុណ្យនេះផង,. ខ្ញុំព្រះករុណាអាត្មាភាពសូមចែកកុសលដែលកើតឡើងអំពីធម្មទាន និងអាមិសទានទាំងពីរប្រការ ចែកប្រគេនជូនចំពោះអស់លោកអ្នកទាំងឡាយ មានឯកឧត្តមជាប្រធាន សូមឲ្យបានសម្រេចផលស្មើៗគាគ្នា កុំបីប្រែក្លាយទៅជាបការៈដទៃឡើយ ! ។

មួយចំណែកទៀត អាត្មាភាពសូមចែកកុសលនេះ ថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិត ដែលព្រះអង្គទ្រង់កំពុងតែពុះពារឧបសគ្គ ដើម្បីស្វែងរកឯករាជ្យដ៏បរិបូណ៌ ឲ្យប្រជារាស្ត្រក្នុងព្រះរាជាណាចក្រទាំងមូលរបស់ទ្រង់ ។ ដោយអំណាចនៃបុញ្ញរាសីនេះ សូមព្រះករុណាជាម្ចាស់ជីវិត អាចដឹកនាំប្រទេសជាតិទាំងមូល ទៅកាន់វឌ្ឍនធម៌និងអារ្យធម៌ ហើយសូមទ្រង់ប្រកបតែនឹងបរមសុខ ក្នុងសិរីរាជសម្បត្តិកុំបីមានឧបសគ្គមកប៉ះពាល់ទ្រង់បានឡើយ ! ។